ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS


សាកលវិទ្យាល័យ វ៉ាន់ដា

VANDA UNIVERSITY


# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ

# PROCEDURES FOR PREVENTING TAXPAYER OFFENSES BY THE GENERAL DEPARTMENT OF TAXATION

## ជំនាញ គណនេយ្យ


រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

ក្រសួងអប់រំ យុវជន និងកីឡា
MINISTRY OF EDUCATION YOUTH AND SPORTS
សាកលវិទ្យាល័យ វ៉ាន់ដា
VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធរបស់ អគ្គនាយកដ្ឋានពន្ធដារ

PROCEDURES FOR PREVENTING THE TAXPAYER OFFENSES BY THE GENERAL DEPARTMENT OF TAXATION

គ្រូណែនាំ៖ សាំង ចេក

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥
PHNOM PENH-2025

# គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២
# ប្រធានបទ៖ នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធ
# របស់អគ្គនាយកដ្ឋានពន្ធដារ

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

សាំង ចេក

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយក
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករង
មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ នៅសាកលវិទ្យាល័យ វ៉ាន់ដា អស់រយៈពេល៤ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ដែលពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យជាពិសេស ក្រុមយើងខ្ញុំបានយល់ច្បាស់ថាជំនាញគណនេយ្យ គឺជាជំនាញមានសារៈសំខាន់មួយដែរសម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តន៍កិច្ចការគណនេយ្យដូចគ្នា។ ដោយឡែក ដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់សាកលវិទ្យាល័យវ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងារគណនេយ្យ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទី១ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យបានយល់ច្បាស់ពីការអនុវត្តន៍ការងារគណនេយ្យ ពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារគណនេយ្យ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួនក្នុងន័យឆ្លើយតប ឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថា កិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំង ស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី"**នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ**" យកមកធ្វើការសិក្សាស្រាវជ្រាវ និងធ្វើការចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែច្បាស់ និងកាន់តែស៊ីជម្រៅពីការរៀបចំសារណា និងប្រសិទ្ធភាពនៃការទប់ស្កាត់បទល្មើសរបស់អ្នកជាប់ពន្ធ។ ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណាមួយនេះឡើង នឹងបានចូលរួមចំណែកមួយក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដទៃទៀតដែលមានគោលបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



វ៉ាន ធារ៉ា
ID: B22/501



ចន្ថា ផាលីម
ID: B22/497



អ៊ូច ជាមាន
ID: B22/983



ខែម គន្ធា
ID: B22/499



ឡួន ស្រីគីន
ID: B22/511

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យវ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញគណនេយ្យ **សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសម្តែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់ នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ឌាសាស្រ្តាចារ្យ លោកគ្រូ អ្នកគ្រូ ទាំងអស់ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅ ដល់ឯកឧត្តមបណ្ឌិត **ហោង វ៉ាន់ដា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យ វ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះគ្រូណែនាំ **សាំង ចេក** ជាគ្រូណែនាំ ដោយបានជួយជ្រោមជ្រែងបង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់គ្រូណែនាំ និងបុគ្គលិកនៃសាកលវិទ្យាល័យវ៉ាន់ដាទាំងអស់ ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតដល់ធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនះ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អំណះអំណាង**

ក្រុមយើងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យ នៃសាកលវិទ្យាល័យ វ៉ាន់ដា ជំនាន់ទី២២៖

សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទស្ដីអំពី "នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ" នេះគឺពិតជាស្នាដៃមួយរបស់ក្រុមនាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលដែលទាក់ទងទៅនឹងការស្រាវជ្រាវ ដែលបានលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃពុធ ៨កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**




វ៉ាន ធារ៉ា

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

នៅលើពិភពលោកបច្ចុប្បន្ន បាននឹងកំពុងអនុវត្តគោលការណ៍ក្នុងការគ្រប់គ្រងប្រព័ន្ធពន្ធដារឱ្យមានប្រសិទ្ធភាពដើម្បីទាក់ទាញការវិនិយោគ និងបង្កើនប្រាក់ចំណូលជូនរដ្ឋ ហេតុដូច្នេះហើយទើបរដ្ឋាភិបាលសម្រេចបង្កើតនូវច្បាប់ស្តីពីសារពើពន្ធសម្រាប់អនុវត្ត។ ដើម្បីធានាបានថាក្រុមហ៊ុន ឬសហគ្រាស ពិតជាបានអនុវត្តតាមច្បាប់ស្តីពីសារពើពន្ធ ដោយមិនមានគោលបំណងក្នុងការគេចវេះពីការបង់ប្រាក់ពន្ធ និងអំពើរាំងស្ទះក្នុងការអនុវត្តបទប្បញ្ញត្តិស្តីពន្ធដារណាមួយ ទើបរដ្ឋបាលសារពើពន្ធបានដាក់ចេញនូវ នីតិវិធីទប់ស្កាត់បទល្មើសរបស់អ្នកជាប់ពន្ធ និងគោលការណ៍ដើម្បីកំណត់បទល្មើសអ្នកជាប់ពន្ធ។

ការបំពានច្បាប់ពន្ធ គឺជាបញ្ហាសំខាន់ដែលរំខានដល់ប្រាក់ចំណូលរបស់រដ្ឋ ដែលជាហេតុទើបប្រព័ន្ធពន្ធដារត្រូវការ ការត្រួតពិនិត្យយ៉ាងម៉ត់ចត់ ដើម្បីទប់ស្កាត់បទល្មើសទាំងនោះ ជាពិសេសទៅលើអ្នកជាប់ពន្ធដែលព្យាយាមលាក់បាំងប្រាក់ចំណូលក្នុងគោលបំណងគេចវេះកាតព្វកិច្ចក្នុងការបង់ប្រាក់ពន្ធ។ និតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធ បានចងក្រងយ៉ាងម៉ត់ចត់នៃមាតិកាពាក់ព័ន្ធនឹងច្បាប់ បទប្បញ្ញត្តិ និងយុទ្ធសាស្ត្រដែលអគ្គនាយកដ្ឋានពន្ធដារ ប្រើប្រាស់ក្នុងការទប់ស្កាត់ នឹងការបំពានច្បាប់ពន្ធដារ។ ដោយឡែកការអនុវត្តនីតិវិធីនានាដូចជាការជម្រុញឱ្យអ្នកជាប់ពន្ធចុះបញ្ជី និងធ្វើបច្ចុប្បន្នភាព ការបង់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិក អនុវត្តការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ និងការផ្តន្ទាទោសតាមច្បាប់ អាចជួយកាត់បន្ថយបទល្មើសពន្ធដារ និងជួយលើកកម្ពស់ទំនុកចិត្តពីសាធារណជន។សៀវភៅនេះមានគោលបំណងបង្ហាញពីសារៈសំខាន់នៃការគ្រប់គ្រងប្រព័ន្ធពន្ធដារ និងការអនុវត្តច្បាប់ពន្ធ ដើម្បីធានាថាការប្រមូលពន្ធមានប្រសិទ្ធភាព យុត្តិធម៌ និងស្មើភាព។

តាមរយៈការសិក្សាស្រាវជ្រាវទៅលើប្រធានបទ**នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធរបស់អគ្គនាយដ្ឋានពន្ធដារ** រួចមក ធ្វើឱ្យយើងអាចសរុបជារួមបានថា នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធរបស់អគ្គនាយដ្ឋានពន្ធដារ ជាសំណុំនៃការរៀបចំវិធានការផ្លូវច្បាប់ដែលអាជ្ញាធរពាក់ព័ន្ធប្រើប្រាស់ដើម្បីស្រាវជ្រាវ ត្រួតពិនិត្យ និងទប់ស្កាត់ការបំពានច្បាប់ពន្ធ ដូចជាការបន្លំពន្ធ ការគេចវេះបង់ពន្ធ ឬបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ផ្សេងៗ។ នីតិវិធីនេះជាផ្នែកមួយនៃការអនុវត្តច្បាប់ពន្ធដើម្បីធានាបាននូវការយកពន្ធត្រឹមត្រូវ និងការពារសិទ្ធិ និងផលប្រយោជន៍របស់រដ្ឋ។ ម្យ៉ាងទៀតឃើញថា រដ្ឋបាលសារពើពន្ធដែលមានអគ្គនាយកដ្ឋានពន្ធដារជាសេនាធិការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានអនុវត្តការងារប្រកបដោយវិជ្ជាជីវៈ មានប្រព័ន្ធបច្ចេកវិទ្យាទំនើប ដែលផ្តល់ភាពងាយស្រួលច្រើនដល់អ្នកជាប់ពន្ធ ដែលជាហេតុនាំឱ្យការប្រមូលពន្ធមានប្រសិទ្ធិភាពខ្ពស់។

# មាតិកា

ទំព័រ

អារម្ភកថា ............ i
របានាសម្ព័នក្រុម............ ii
សេចក្តីថ្លែងអំណរគុណ ............ iii
អំណះអំណាង ............ iv
សេចក្តីសង្ខេបនៃការស្រាវជ្រាវ ............ v
មាតិកា............ vi

## ជំពូកទី១
## សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ............ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ............ ១
១.៣ គោលបំណងនៃការស្រាវជ្រាវ............ ២
១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ............ ២
១.៤.១ ទំហំដែនកំណត់............ ២
១.៤.២ វិសាលភាពនៃការស្រាវជ្រាវ............ ២
១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ............ ២
១.៥.១ ការប្រមូលទិន្នន័យដំបូង............ ២
១.៥.២ ការប្រមូលទិន្នន័យបន្ទាប់ ............ ២
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ............ ៣
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ............ ៤

## ជំពូកទី២
## នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធ

២.១ លក្ខណៈទូទៅនៃពន្ធ............ ៥
២.១.១ និយមន័យពន្ធ ............ ៥
២.១.២ ប្រវត្តិនៃពន្ធ ............ ៥
២.១.៣ ប្រភេទនៃពន្ធ............ ៥
២.១.៤ សារៈសំខាន់នៃពន្ធ ............ ១៧
២.២ នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធ ............ ១៨
២.២.១ និយមន័យនីតិវិធី............ ១៨
២.២.២ ប្រវត្តិនីតិវិធី............ ១៨
២.២.៣ ទ្រឹស្តីនីតិវិធី............ ១៩

២.២.៤ តួនាទីរបស់នីតិវិធី.....................................................................................២០
២.៣ គោលការណ៍ដើម្បីកំណត់បទល្មើសអ្នកជាប់ពន្ធ...............................................................២០
២.៣.១ និយមន័យអ្នកជាប់ពន្ធ.....................................................................................២០
២.៣.២ ប្រវត្តិអ្នកជាប់ពន្ធ.............................................................................................២១
២.៣.៣ ទ្រឹស្តីអ្នកជាប់ពន្ធ.............................................................................................២២

## ជំពូកទី៣

## នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ

៣.១ ស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ.....................................................................២៣
៣.១.១ ប្រវត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ.........................................................................២៣
៣.១.២ បេសកកម្ម ទស្សនវិស័យ និងភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ.........................២៥
៣.១.៣ រចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ.............................................................២៦
៣.២ នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ...........................២៦
៣.២.១ ការចុះបញ្ជី និងការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ..........................................២៦
៣.២.២ ការបង់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិក.....................................................................២៧
៣.២.៣ វិសាលភាព បែបបទ និងនីតិវិធីនៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ...............................................................................................................២៨
៣.៣ គោលការណ៍ដើម្បីកំណត់បទល្មើសអ្នកជាប់ពន្ធ...............................................................៣១
៣.៣.១ បទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ..................................................៣១
៣.៣.២ គោលការណ៍កំណត់បទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ....................៣២
៣.៣.៣ ទណ្ឌកម្មព្រហ្មទណ្ឌតាមបទប្បញ្ញត្តិស្តីពីពន្ធដារ.................................................៣៣

## ជំពូកទី៤: ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង.....................................................................................៣៥
៤.២ ការវិភាគលើចំណុចខ្សោយ...................................................................................៣៥

## ជំពូកទី៥: សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន..............................................................................................៣៧
៥.២ ការផ្តល់អនុសាសន៍ ...........................................................................................៣៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងពិភពលោកមានប្រទេសជាច្រើន ដែលមានមនុស្សរស់នៅគ្រប់ពូជសាសន៍ ពណ៌សម្បុរចម្រុះគ្នា។ ប្រទេសទាំងនោះតែងតែរងនូវភ្លើងសង្គ្រាមដែលកើតមានឡើងពីការដណ្តើមអំណាច ពង្រីកទឹកដី ប្រកាន់សាសនា ប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ។ល។ សង្គ្រាមទាំងនោះធ្វើឱ្យមនុស្សរងទុក្ខវេទនាបែកបាក់ ជាពិសេស គឺសេដ្ឋកិច្ចសកល មានការថយចុះយ៉ាងខ្លាំង ក្នុងនោះក៏មាន ប្រទេសកម្ពុជាផងដែរ ដែលជាប្រទេសធ្លាប់រងទុក្ខនៅក្នុងភ្លើងសង្គ្រាមអស់ជាច្រើនសម័យកាលកន្លងមក និងបានទទួលរងឥទ្ធិពលពីភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកលជាច្រើនឆ្នាំ។ ក្រោយពីបញ្ចប់ភ្លើងសង្គ្រាមប្រទេសជាតិ មានការផ្លាស់ប្តូរនូវមុខមាត់ថ្មី តាមរយៈការអភិវឌ្ឍប្រទេសជាតិឱ្យកាន់តែរីកចម្រើន រាជរដ្ឋាភិបាលបានរៀបចំ និងបន្តកែប្រែប្រព័ន្ធគ្រប់គ្រង គោលនយោបាយ ច្បាប់ និងបទបញ្ញត្តិថ្មីៗសម្រាប់ដឹកនាំប្រទេសជាតិ ក្នុងនោះក៏មានប្រព័ន្ធពន្ធដារ " **អគ្គនាយកដ្ឋានពន្ធដារ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**" បានបង្កើតឡើងក្នុងគោលដៅធ្វើការប្រមូលចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ ពីប្រជាពលរដ្ឋ និងពីបណ្តាក្រុមហ៊ុនដែលកំពុងធ្វើសកម្មភាពអាជីវកម្ម ដើម្បីបំពេញចំណាយសាធារណៈ ដូចជាសាងសង់មន្ទីរពេទ្យ បើកប្រាក់ខែជូនមន្ត្រីរាជការ និងយកទៅអភិវឌ្ឍប្រទេសជាតិ។

នៅក្នុងបរិបទនៃការអភិវឌ្ឍប្រទេសកម្ពុជាបានធ្វើការកែទម្រង់ប្រព័ន្ធពន្ធដារជាបន្តបន្ទាប់ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច និងរក្សាការប្រមូលចំណូលពន្ធនៅកម្រិតខ្ពស់។ ទោះបីជាយ៉ាងណាក៏ដោយ ក៏នៅតែមានបញ្ហាប្រឈមចំពោះបទល្មើសពន្ធដារ ដូចជា សកម្មភាពគេចវេះ និងបន្លំពន្ធ ដែលធ្វើឱ្យប្រព័ន្ធពន្ធខាតបង់ចំណូលដ៏មានតម្លៃសម្រាប់ការអភិវឌ្ឍប្រទេស។ ដើម្បីទប់ស្កាត់បញ្ហានេះ ទើបនីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធត្រូវបានអភិវឌ្ឍ និងអនុវត្តដោយផ្តោតលើវិធានការរឹងមាំដូចជា ការកែប្រែច្បាប់ពន្ធដារ ការពង្រឹងការត្រួតពិនិត្យ និងអនុលោមភាពពន្ធដារការចងសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធ និងការប្រើប្រាស់បច្ចេកវិទ្យាទំនើបក្នុងការតាមដាន។ នីតិវិធីទប់ស្កាត់បទល្មើសពន្ធដារ មិនត្រឹមតែជួយកាត់បន្ថយការបាត់បង់ចំណូលពន្ធប៉ុណ្ណោះទេ វាក៏ជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍប្រទេសទៅកាន់ភាពរីកចម្រើនលើវិស័យសេដ្ឋកិច្ច សង្គម និងហេដ្ឋារចនាសម្ព័ន្ធ។

ហេតុដូច្នេះហើយ ទើបក្រុមនាងខ្ញុំ បានជ្រើសរើសប្រធានបទ "**នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ**" សម្រាប់ការសរសេរបញ្ចប់ឆ្នាំសិក្សា។ ជាប្រធានបទមួយដែលអាចឱ្យក្រុមនាងខ្ញុំបានស្រាវជ្រាវយល់ដឹងពីនីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធ យុទ្ធសាស្ត្រនៃការប្រមូលពន្ធ និងការផ្សព្វផ្សាយពីច្បាប់ពន្ធទៅឱ្យបុគ្គលជាប់ពន្ធ និងសហគ្រាសមួយចំនួនឱ្យបានយល់កាន់តែច្បាស់នៅអត្រាជាប់ពន្ធរបស់ខ្លួនដើម្បីបង់ពន្ធជូនរដ្ឋ និងរួមចំណែកតូចមួយសម្រាប់អភិវឌ្ឍប្រទេសជាតិយើងផង។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីដោះស្រាយនូវបញ្ហាមួយចំនួនដែលប្រជាពលរដ្ឋប្រព្រឹត្តបទល្មើស និងគេចវេះមិនព្រមបង់ពន្ធនិងមានការត្អូញត្អែរដែលកើតមានឡើងដោយចេតនារបស់អ្នកជាប់ពន្ធ ឬបទល្មើសជាក់ស្តែងដែលអ្នកជាប់ពន្ធបាន និងកំពុងប្រព្រឹត្ត អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវនីតិវិធីក្នុងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទ

ប្បញ្ញត្តិស្តីពីពន្ធដារទៅលើអ្នកជាប់ពន្ធ។ ដើម្បីសម្រេចបាននូវនីតិវិធីនេះ អគ្គនាយកដ្ឋានពន្ធដារបានធ្វើការកែទម្រង់យុទ្ធសាស្ត្រជាច្រើនដែលស្របតាមសម័យនគូបនីយកម្ម ដើម្បីផ្តល់សេវាដល់អ្នកជាប់ពន្ធឱ្យកាន់តែមានប្រសិទ្ធភាពដូចជា ការផ្តល់ព័ត៌មានអប់រំ ពន្យល់ណែនាំដើម្បីឱ្យអ្នកជាប់ពន្ធប្រតិបត្តិ និងអនុវត្តត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារដល់អ្នកជាប់ពន្ធឱ្យកាន់តែយល់ច្បាស់ជៀសវាងការគេចវេះពីកាតព្វកិច្ចសារពើពន្ធដែលនាំឱ្យបាត់បង់ចំណូលពន្ធ ហេតុដូចនេះហើយ ការដាក់ចេញនីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធជាចំណុចសំខាន់មួយដើម្បីបង្កើនចំណូលពន្ធ។

១. តើរដ្ឋបាលសារពើពន្ធមាននីតិវិធីក្នុងការទប់ស្កាត់បទល្មើសរបស់អ្នកជាប់ពន្ធយ៉ាងដូចម្តេចខ្លះ?

២. តើរដ្ឋបាលសារពើពន្ធមានគោលការណ៍បែបណាខ្លះដើម្បីកំណត់ពីបទល្មើសរបស់អ្នកជាប់ពន្ធ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គម្រោងការនេះធ្វើឡើងក្នុងគោលបំណង ដើម្បីស្វែងយល់ដឹងបន្ថែមឱ្យកាន់តែច្បាស់លាស់អំពីប្រព័ន្ធពន្ធដារ និងបទល្មើសអ្នកជាប់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ ធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋ៖

-យល់ដឹងអំពីបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារកាន់តែច្បាស់

-យល់ដឹងអំពីនីតិវិធីទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធ

-យល់ដឹងអំពីគោលការណ៍ទប់ស្កាត់ការគេចវេះមិនបង់ពន្ធ

-យល់ដឹងអំពីគោលការណ៍កំណត់បទល្មើសព្រហ្មទណ្ឌលើបទបញ្ញត្តិស្តីពីពន្ធដារ

-យល់ដឹងអំពីបែបបទនិងនីតិវិធីនៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ

-យល់ដឹងអំពីទណ្ឌកម្មព្រហ្មទណ្ឌតាមបទប្បញ្ញត្តិស្តីពីពន្ធដារ

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំដែនកំណត់

ការស្រាវជ្រាវនេះ គឺសិក្សាអំពីនីតីវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធ និងច្បាប់មួយចំនួនដែលទាក់ទងនឹងសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ រៀបចំ និងបោះផ្សាយដោយ អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ២០១០ និងសៀវភៅណែនាំស្តីពី បែបបទ និងនីតិវិធីនានា នៅក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ ។ អគ្គនាយកដ្ឋានពន្ធដារមានអាស័យដ្ឋាននៅ អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី(១១០) និងម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ស្វែងយល់ពីនីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ រួមទាំងសិទ្ធិ និងបែបបទនានា រក្សាសិទ្ធិដោយអគ្គនាយកដ្ឋានពន្ធដារ បោះពុម្ពផ្សាយ ឆ្នាំ២០២៤។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវបានប្រើប្រាស់តាមវិធីសាស្ត្រគុណវិស័យដោយផ្តោតចម្បងទៅលើការប្រមូលទិន្នន័យ និងឯកសារដែលពាក់ព័ន្ធទៅនឹងប្រធានបទដើម្បីយកមកវិភាគ និងសិក្សាស្រាវជ្រាវក្នុងគោលបំណងបញ្ជាក់ អំពីនីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ។

សម្រាប់សំណួរស្រាវជ្រាវទី១៖ ការស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យដូចជា ការប្រមូលទិន្នន័យកម្រងឯកសារនានា វិធីសាស្ត្រស្រាវជ្រាវតាមរយៈគេហទំព័រ បណ្តាញសង្គមរបស់អគ្គនាយកដ្ឋាន

ពន្ធដារផ្ទាល់ ការសិក្សាស្រាវជ្រាវព័ត៌មានខ្លះៗបានមកពីបណ្ណាល័យរបស់សាកលវិទ្យាល័យ វ៉ាន់ដា ការដកស្រង់នូវឯកសារមេរៀនទាំងឡាយណាដែលពាក់ព័ន្ធនឹងប្រធានបទ ការអានកម្រងឯកសារផ្សេងៗ ឯកសារចាស់ៗដែលសិស្សច្បងជំនាន់មុនបានធ្វើរួច និងធ្វើការសាកសួរទៅគ្រូណែនាំបន្ថែម។

សម្រាប់សំណួរស្រាវជ្រាវទី២៖ ការស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យដូចជា ការប្រមូលទិន្នន័យ កម្រងឯកសារនានា វិធីសាស្ត្រស្រាវជ្រាវតាមរយៈគេហទំព័រ បណ្ដាញសង្គមរបស់អគ្គនាយកដ្ឋានពន្ធដារផ្ទាល់ ការសិក្សាស្រាវជ្រាវព័ត៌មានខ្លះៗបានមកពីបណ្ណាល័យរបស់សាកលវិទ្យាល័យ វ៉ាន់ដា ការដកស្រង់នូវ ឯកសារមេរៀនទាំងឡាយណាដែលពាក់ព័ន្ធ នឹងប្រធានបទ ការអានកម្រងឯកសារផ្សេងៗ ឯកសារចាស់ៗដែលសិស្សច្បងជំនាន់មុនបានធ្វើរួច និងធ្វើការសាកសួរទៅគ្រូណែនាំបន្ថែម។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

តាមការសិក្សាស្រាវជ្រាវនេះបានឆ្លុះបញ្ចាំងអំពីសារៈសំខាន់ និងអត្ថប្រយោជន៍ជាច្រើនដូចជា៖

**ក.សម្រាប់អ្នកស្រាវជ្រាវ**

-យល់ដឹងអំពីស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ

-យល់ដឹងអំពីនីតិវិធីទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធ

-យល់ដឹងអំពីបែបបទនិងនីតិវិធីនៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ

-យល់ដឹងអំពីបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារកាន់តែច្បាស់

-យល់ដឹងអំពីគោលការណ៍ទប់ស្កាត់ការគេចវេះមិនបង់ពន្ធ

-ចេះវិភាគចំណុចខ្លាំងនិងចំណុចខ្សោយ

-បង្កើននូវចំណេះដឹងផ្ទាល់ខ្លួន និងការផ្ដល់អនុសាសន៍

-ពង្រីកចំណេះដឹងបន្ថែមក្នុងការស្រាវជ្រាវ។

**ខ.សម្រាប់អគ្គនាយកដ្ឋានពន្ធដារ**

-បង្កើនប្រាក់ចំណូលពន្ធ

-ធ្វើឱ្យការប្រមូលពន្ធប្រកបដោយប្រសិទ្ធភាព

-ធ្វើឱ្យមានតម្លាភាពក្នុងការអនុវត្តច្បាប់ស្តីពីសារពើពន្ធ

-បង្កើនទំនុកចិត្តពីសាធារណជន

-រក្សាប្រព័ន្ធពន្ធដារឱ្យមានប្រសិទ្ធភាព

**គ.សម្រាប់សង្គម**

-ធានាថាសេដ្ឋកិច្ចជាតិមានស្ថិរភាព និងមានការអភិវឌ្ឍ

-បង្កើនសមភាព និងយុត្តិធម៌ក្នុងសង្គម

-បង្កើនទំនុកចិត្តរបស់សាធារណជនលើរដ្ឋាភិបាល

-ការពារអត្ថប្រយោជន៍សាធារណៈ

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវនេះត្រូវបានគេបែងចែកជា៥ជំពូកមានដូចជា៖

-ជំពូកទី១ សេចក្តីផ្តើម៖ ជំពូកទីមួយបានបង្ហាញអំពី លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ទំហំ និងដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

-ជំពូកទី២៖ រំលឹកទ្រឹស្តី៖ ជំពូកទីពីរនេះបានបង្ហាញពីការលើកឡើងនៃនិយមន័យ ប្រវត្តិ និងទ្រឹស្តីពាក់ព័ន្ធនឹងនីតិវិធី និងអ្នកជាប់ពន្ធ។

-ជំពូកទី៣៖ លិទ្ធផលនៃការស្រាវជ្រាវ៖ ជំពូកនេះបានលើកឡើងពីប្រវិត្តនៃការកកើតរបស់អគ្គនាយកដ្ឋានពន្ធដារ បេសកកម្ម ទស្សនវិស័យ និងគោលដៅរបស់អគ្គនាយកដ្ឋានពន្ធដារ ច្បាប់ និងបទបញ្ញត្តិនានាដែលទាក់ទងនិងនីតិវិធីក្នុងការទប់ស្កាត់បទល្មើសរបស់អ្នកជាប់ពន្ធ។

- ជំពូកទី៤៖ ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ បង្ហាញពីការធ្វើការវិភាគចំណុចខ្លាំង និងចំណុចខ្សោយនៅក្នុងជំពូកទី៣ ដែលបានស្រាវជ្រាវមក។

- ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ បង្ហាញពីការសន្និដ្ឋានគ្រប់ជ្រុងជ្រោយទាំងចំណុចខ្លាំង និងចំណុចខ្សោយ ថែមទាំងផ្តល់អនុសាសន៍ទៅលើចំណុចខ្សោយផងដែរ។

# ជំពូកទី២
# នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធ

## ២.១ លក្ខណៈទូទៅនៃពន្ធ

### ២.១.១ និយមន័យពន្ធ

**ពន្ធ** គឺជាកាតូកិច្ចបង់ជាប្រាក់ ឬវត្ថុរបស់អ្នកជាប់ពន្ធទៅរដ្ឋាភិបាល ហើយអ្នកជាប់ពន្ធទាំងនោះទទួល តម្លៃតបស្នងពីរដ្ឋាភិបាលវិញតាមរយៈទំនិញ និងសេវាសាធារណៈ[1]។

**ពន្ធ** គឺជាបន្ទុករបស់ប្រជាពលរដ្ឋបង់ចូលថវិកាជាតិ ប្រជាពលរដ្ឋគ្រប់រូបមានកាតព្វកិច្ចបង់ពន្ធជូនរដ្ឋ។

**ពន្ធ** ជាឧបករណ៍របស់រដ្ឋាភិបាលដែលបានបង្កើតឡើង ដើម្បីកៀរគរចំណូលចូលថវិការជាតិសម្រាប់ចំណាយសាធារណៈ។

**ពន្ធ** សំដៅដល់ពន្ធអាករ (ពន្ធផ្ទាល់ និងពន្ធប្រយោល)។

### ២.១.២ ប្រវត្តិនៃពន្ធ

ការយកពន្ធត្រូវបានគេស្គាល់ជាលើកដំបូងបានកើតឡើងនៅប្រទេសអេហ្ស៊ីបបុរាណនៅប្រហែល ៣០០០-២៤០០ មុន គ.ស ដែលមានឈ្មោះជាអក្សរឡាតាំងថា Taxo។ បណ្តាលប្រទេសភាគច្រើនមានប្រព័ន្ធពន្ធនៅកន្លែងដើម្បីចំណាយសម្រាប់តម្រូវការសាធារណៈទូទៅ ឬដែលបានព្រមព្រៀងគ្នា និងមុខងាររបស់រដ្ឋាភិបាល។ ការយកពន្ធខ្លះអត្រាភាគរយគិតជាភាគរយនៃការយកពន្ធប្រាក់ចំណូលប្រចាំឆ្នាំផ្ទាល់ខ្លួន ប៉ុន្តែពន្ធខ្នាតភាគច្រើនផ្អែកលើ ចំនួនប្រាក់ចំណូលប្រចាំឆ្នាំ។ ប្រទេសភាគច្រើនគិតពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំរបស់បុគ្គលម្នាក់ៗ ក៏ដូចជាពន្ធលើប្រាក់ចំណូលរបស់ក្រុមហ៊ុនផងដែរ[2]។

ពន្ធមានលក្ខណៈបង្ខំ ហើយមិនសងឱ្យវិញផ្ទាល់ឡើយ ប៉ុន្តែនិងអាចសងឱ្យវិញជាលក្ខណៈរូបភាពប្រយោលទៅតាមគោលនយោបាយរដ្ឋាភិបាលប្រទេសនីមួយៗ។ គ្រប់អង្គភាពអាជីវកម្ម ផលិតកម្ម សេវាកម្មដែលចំណុះឱ្យគ្រប់សមាសភាពសេដ្ឋកិច្ច ត្រូវមានកាតូកិច្ច និងទំនួលខុសត្រូវចំពោះមុខច្បាប់។ ហើយមានសិទ្ធិស្មើៗគ្នា ក្នុងការទទួលមកវិញនូវផលប្រយោជន៍ពី រដ្ឋាភិបាលដែលប្រកបដោយយុត្តិធម៌ និង ត្រូវបានរដ្ឋាភិបាលបង្កលក្ខណៈងាយស្រួលមកវិញតាមរយៈ គោលនយោបាយដែលមានបែងចែកក្នុងច្បាប់ [3]។

### ២.១.៣ ប្រភេទនៃពន្ធ

សិល្បវិធីសម្រាប់ដកហូតពន្ធពីប្រជាពលរដ្ឋចែកចេញជាពីរប្រភេទគឺ៖

១. ពន្ធដោយផ្ទាល់ ឬពន្ធចំពោះ៖ គឺជាប្រភេទពន្ធដែលរដ្ឋដកហូតពីប្រជាពលរដ្ឋ ដែលជាជនទី១។

២. ពន្ធប្រយោល៖ គឺជាប្រភេទពន្ធដែលរដ្ឋដកហូតពីជនទី២ តាមរយៈជនទី១។

ពន្ធ និងអាករនៅព្រះរាជាណាចក្រកម្ពុជារួមមាន៖

ពន្ធរួមមាន៖

---

[1] វិទ្យាស្ថាន វ៉ាន់ដា. *ច្បាប់ពន្ធដារប្រទេសកម្ពុជា.* បោះពុម្ពផ្សាយ២០២៣. ៥៨ទំព័រ។

[2] BIRMISS. (2018). *ពន្ធនៅក្នុងប្រទេសអេហ្ស៊ីបបុរាណជាអ្វី.* Retrieved from https://km.birmiss.com (Accessed 13.03.25)

[3] CamboFinance. (2019, November 4). *ហេតុអ្វីបានជាយើងត្រូវបង់ពន្ធ* Retrieved from https://www.facebook.com/share/1Byf69xyt5/ (Accessed 13.03.25)

**១. ពន្ធលើប្រាក់ចំណូល** គឺត្រូវបានកំណត់លើអ្នកជាប់ពន្ធនិវាសនជន ចំពោះប្រាក់ចំណូល ប្រភពកម្ពុជា និងប្រាក់ចំណូលប្រភពបរទេស។ សម្រាប់អ្នកជាប់ពន្ធអនិវាសនជន ពន្ធលើប្រាក់ចំណូល កំណត់តែលើប្រាក់ចំណូលប្រភពកម្ពុជាប៉ុណ្ណោះ។

អត្រាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំរបស់ក្រុមហ៊ុននីមួយៗ

- 0% : ចំពោះប្រាក់ចំណូលជាប់ពន្ធរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) (Qualified Investment Project) ដែលស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធ (Tax Holiday) ពីCDC ( Council for the Development of Cambodia)។
- ៥% : សម្រាប់ក្រុមហ៊ុនធានារ៉ាប់រង។
- ២០% : ចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានដោយនីតិបុគ្គល (ប្រភេទក្រុមហ៊ុនសេវាកម្ម ពាណិជ្ជកម្ម ផលិតកម្ម)
- ៣០% : ចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានក្រោមកិច្ចសន្យាបែងចែកផលិតផលប្រេងកាត និងឧស្ម័ន ធម្មជាតិ ឬសម្រេចបានពីការធ្វើអាជីវកម្មលើធនធានធម្មជាតិ រួមទាំងព្រៃឈើ រ៉ែមាស ឬត្បូងថ្មមានតម្លៃនានា
- អត្រាកំណើនតាមថ្នាក់( ពី0% - 20% ) ចំពោះក្រុមហ៊ុននីតិបុគ្គល ( សហគ្រាសឯកបុគ្គល )[4]។

<u>អត្រាពន្ធលើប្រាក់ចំណូល កំណើនតាមថ្នាក់សំរាប់សហគ្រាសឯកបុគ្គល</u>

| | | | | |
|---|---|---|---|---|
| . 0 | ⇒ | 18,000,000៛ | ⇒ | ( 0% ) |
| . 18,000,000៛ | ⇒ | 24,000,000៛ | ⇒ | ( X x 5% )– 900,000៛ |
| . 24,000,001៛ | ⇒ | 102,000,000៛ | ⇒ | ( X x 10% )– 2,100,000៛ |
| . 102,000,001៛ | ⇒ | 150,000,000៛ | ⇒ | ( X x15% )– 7,200,000៛ |
| .150,000,001៛ | ⇒ | ឡើងទៅ | ⇒ | ( X x 20% )– 14,700,000៛ |

**២. ពន្ធប្រាក់រំដោះលើប្រាប់ចំណូល** គឺជាពន្ធប្រចាំខែអត្រា១% ដែលបានមកពីចំណូល អាជីវកម្ម និងចំណូលបន្ទាប់បន្សំរួមទាំងអាករនានា លើកលែងអាករលើតម្លៃបន្ថែម [5]។

### ❈ រូបមន្តគិតពន្ធ

ពន្ធប្រាក់រំដោះលើប្រាក់ចំណូល = ( ចំណូលអាជីវកម្ម + ចំណូលបន្ទាប់បន្សំ ) x 1%

**៣. ពន្ធអប្បបរមា** គឺជាពន្ធដែលកំណត់លើអ្នកជាប់ពន្ធតាមរបបពិត។ ពន្ធអប្បរមា ជាពន្ធមួយដាច់ដោយឡែក និងផ្សេងពីពន្ធលើប្រាក់ចំណូល។ ពន្ធអប្បបរមា ត្រូវកំណត់ស្មើនឹង ១% នៃផលរបរ ប្រចាំឆ្នាំ រួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែ អាករលើតម្លៃបន្ថែម ចំពោះតែសហគ្រាសទាំងឡាយណា ដែលមិនកាន់បញ្ជីការគណនេយ្យបានត្រឹមត្រូវ [6]។

[4]សាកលវិទ្យាល័យវ៉ាន់ដា. *ច្បាប់ពន្ធដារប្រទេសកម្ពុជា* . បោះពុម្ពផ្សាយ២០២៣. ១៨៨ទំព័រ។

[5] សាកលវិទ្យាល័យវ៉ាន់ដា:. *គណនេយ្យអនុវត្តន៍ និងពន្ធ* . បោះពុម្ពលើកទី៣ ឆ្នាំ២០២២. ១៩០ទំព័រ. ភ្នំពេញ។

[6] KHSEARCH. ពន្ធ. (2020, January 21). *តើអ្វីជាពន្ធអប្បបរមា*. Retrieved from https://www.khsearch.com/qna/28549 (Accessed 11.03.25)

**៤. ពន្ធលើឈ្នួលផ្ទះ និងដី** សំដៅដល់ប្រាក់ឈ្នួលជុលដែលបានចុះកិច្ចសន្យា ឬបានព្រមព្រៀងជាមួយអ្នកជួលដោយផ្អែកលើតម្លៃទីផ្សារ។

ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ ត្រូវបានកំណត់ទៅលើប្រាក់ឈ្នួលដែលបានមកពីការជួលអចលនទ្រព្យដែលត្រូវប្រមូលពីកម្មសិទ្ធិករ ឬសិទ្ធិវន្តរបស់កម្មសិទ្ធិករ។

ពន្ធនេះត្រូវបានប្រមូលសម្រាប់ជាគុណប្រយោជន៍ថវិកាថ្នាក់ក្រោមជាតិ (ប្រកាសលេខ១៤៣១ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧) ។

**❈ ការលើកលែងពន្ធ**

១. ថ្លៃឈ្នួលពីការជួលអចលនទ្រព្យរបស់រាជរដ្ឋាភិបាល ឬក្រសួងស្ថាប័នរាជរដ្ឋាភិបាល។

២. ថ្លៃឈ្នួលពីការជួលអចលនទ្រព្យរបស់បេសកកម្មការទូត ឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលដទៃទៀត។

៣. ថ្លៃឈ្នួលពីការជួលអចលនទ្រព្យរបស់អង្គការ ឬសមាគមណាមួយដែលៈ

ក- ត្រូវបានរៀបចំឡើង និងដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬអប់រំ។

ខ- គ្មានចំណែកណាមួយនៃថ្លៃឈ្នួលត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជន។

៤. ប្រាក់ដែលអ្នកជួលបានតម្កល់ទុកធ្វើជាប្រាក់ធានា ហើយនៅពេលចប់កិច្ចសន្យាកម្មសិទ្ធិករត្រូវប្រគល់គ្រប់ចំនួនឱ្យអ្នកជួលវិញ។

៥. ថ្លៃឈ្នួលដែលបានកាត់ទុកប្រាក់ពន្ធរួចហើយដោយសហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសតាមមាត្រា២៥ និងមាត្រា២៦ នៃចសព។

៦. ថ្លៃឈ្នួលពីការជួលអចលនទ្រព្យរបស់សហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលបានគិតបញ្ចូលក្នុងប្រាក់ចំណូលជាប់ពន្ធរបស់សហគ្រាសរួចហើយ។

៧.ប្រាក់ឈ្នួលប្រចាំខែក្រោម៥០០ ០០០ រៀល។

**❈ មូលដ្ឋានគិតពន្ធ អត្រាពន្ធ និងការគណនាពន្ធ**

- មូលដ្ឋានគិតពន្ធនេះ ផ្អែកលើថ្លៃជួលជុលសរុបប្រចាំខែ
- ថ្លៃជួលជុលសំដៅលើតម្លៃដែលបានកំណត់ក្នុងកិច្ចសន្យា ឬតម្លៃដែលបានឯកភាពគ្នារវាងអ្នកជួល និងម្ចាស់កម្មសិទ្ធិ
- ប្រាក់កក់ធានាមិនត្រូវបានរាប់បញ្ចូលក្នុងថ្លៃជួលជុលនេះទេ
- ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យត្រូវបានអនុវត្តតាមអត្រា១០%
- ពន្ធត្រូវបង់ = មូលដ្ឋានគិតពន្ធ×១០% [7]។

**៥. ពន្ធកាត់ទុកទូទៅ** គឺជាប្រភេទពន្ធប្រយោលដែលរដ្ឋដកហូតពី អ្នកផ្គត់ផ្គង់និវាសនជន ឬអនិវាសនជន តាមរយៈអ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម។

អ្នកផ្គត់ផ្គង់ចែកជាពីរប្រភេទៈ អ្នកផ្គត់ផ្គង់និវាសនជន

[7] វិទ្យាស្ថាន វ៉ាន់ដា. *ច្បាប់ពន្ធដារប្រទេសកម្ពុជា.* បោះពុម្ពផ្សាយ២០២៣ ១៨៨ទំព័រ

-នីតិបុគ្គលនិវាសនជនៈ ក្រុមហ៊ុនដែលមាន ដែលបានបង្កើត និងគ្រប់គ្រងក្នុងកម្ពុជា។

-រូបវន្តបុគ្គលនិវាសនជនៈ គឺមានទីកន្លែងស្នាក់នៅជាគោលដើម ឬមាននិវាសនដ្ឋាន ឬមានវត្តមានក្នុងកម្ពុជាលើស១៨២ថ្ងៃក្នុងឆ្នាំប្រតិទិនចរន្ត។

-អ្នកផ្គត់ផ្គង់អនិវាសនជន គឺជាអ្នកផ្គត់ផ្គង់មិនមែននិវាសនជន។

❈ **មូលដ្ឋានគិតពន្ធ**

+ពន្ធកាត់ទុកលើនិវាសនជនៈ ត្រូវបែកចែកជា ៦ ចំណុចគឺៈ

.ការបំពេញសេវានានា និងសួយសារចំពោះទ្រព្យអរូបី ភាគកម្មធនធានរ៉ែ១៥%

.ការបង់ការប្រាក់ទៅឱ្យអ្នកជាប់ពន្ធ មិនមែនជាស្ថាប័នធនាគារ១៥% .

.កាប្រាក់ដែលធនាគារបង់ឱ្យអ្នកជាប់ពន្ធដែលមានគណនីសន្សំមានកាលកំណត់៦%

.កាប្រាក់ដែលធនាគារបង់ឱ្យអ្នកជាប់ពន្ធដែលមានគណនីសន្សំគ្មានកាលកំណត់៤%

.ថ្លៃឈ្នួលចលនទ្រព្យ និងអចលនទ្រព្យ១០% សម្រាប់(រូបវន្តបុគ្គល)

.ថ្លៃឈ្នួលចលនទ្រព្យ និងអចលនទ្រព្យ១០% សម្រាប់( នីតិបុគ្គល)

+ពន្ធកាត់ទុកលើអនិវាសនជនៈ ត្រូវបែកចែកជា ៥ ចំណុច តាមអត្រា១៤% គឺៈ

.ការបង់ការប្រាក់ ការបង់សួយសារ ថ្លៃឈ្នួល ចំណូលផ្សេងៗទាក់ទិន នឹងការប្រើប្រាស់ទ្រព្យសម្បត្តិ

.ការទូរទាត់ថ្លៃសេវាគ្រប់គ្រង និងសេវាបច្ចេកទេសនានា

.ការបង់ភាគលាភ

.សេវាកម្ម [8]។

**៦. ពន្ធលើប្រាក់បៀវត្ស & អត្ថប្រយោជន៍បន្ថែម** គឺជាប្រភេទពន្ធប្រយោលដែលរដ្ឋដកហូតពីនិយោជិតនិវាសនជនដែលមានបៀវត្សប្រភពកម្ពុជា និងប្រភពក្រៅកម្ពុជា និងនិយោជិតអនិវាសនជនដែលមានបៀវត្សប្រភពកម្ពុជា តាមរយៈនិយោជកនិវាសនជន។ អត្ថប្រយោជន៍បន្ថែមរួមមាន ទំនិញនិងសេវា ឬអត្ថប្រយោជន៍ជាសាច់ប្រាក់ ឬវត្ថុផ្សេងទៀតដែលនិយោជកផ្តល់ឱ្យដោយផ្ទាល់ ឬប្រយោលដល់រូបវន្តបុគ្គលចំពោះសកម្មភាពបម្រើការងារ។

- ជារៀងរាល់ខែនិយោជកត្រូវកាត់ទុកពន្ធតាមអត្រា២០% ។
- តម្លៃអត្ថប្រយោជន៍បន្ថែម គឺជាតម្លៃទីផ្សាររួមទាំងពន្ធអាករទាំងអស់ហើយត្រូវជាប់ពន្ធក្នុងខែបានផ្តល់ឱ្យនិយោជិត។

**អត្ថប្រយោជន៍បន្ថែមទាំងនោះមានជាអាទិ៍ៈ**

.យានជំនិះគ្រប់ប្រភេទ

.ម្ហូបអាហារ លំនៅដ្ឋាន ការស្នាក់នៅ ទឹក ភ្លើង ទូរស័ព្ទ

.អ្នកបម្រើការងារក្នុងលំនៅដ្ឋាន

.ប្រាក់ឱ្យខ្ចីដោយគិតការប្រាក់ទាបជាងការប្រាក់ទីផ្សារ អត្រាការប្រាក់ទីផ្សារកំណត់ដោយ ក្រសួងសហវ

[8] វិទ្យាស្ថាន វ៉ាន់ដា. ឆ្នាំ២០២២. *គណនេយ្យអនុវត្តន៍ និងពន្ធ*. បោះពុម្ពផ្សាយលើកទី៣. ១៩០ទំព័រ. ភ្នំពេញ។

.ការលក់ទំនិញចុះថ្លៃ

.ជំនួយផ្នែកអប់រំសម្រាប់និយោជិត ដែលមិនមែនជាចំណែកណាមួយនៃកម្មវិធីបណ្តុះបណ្តាលទាក់ទងផ្ទាល់ទៅនឹងការបំពេញការងាររបស់និយោជិតនោះ

.ជំនួយផ្នែកអប់រំសម្រាប់កូនរបស់និយោជិត

.បុព្វលាភធានារ៉ាប់រងអាយុជីវិត ឬសុខភាព លើកលែងតែមានផ្តល់អត្ថប្រយោជន៍បន្ថែមដូចគ្នាឱ្យដល់និយោជិតគ្រប់គ្នាដោយគ្មានការបែងចែកតាមតួនាទី ឬមុខងារ

.ចំណែកនៃការឧបត្ថម្ភលើចំណាយ ដែលមិនសមហេតុផល និងមិនចាំបាច់សម្រាប់អាជីវកម្ម

.ចំនួនប្រាក់បង់ចូលមូលនិធិសុខមាលភាពសង្គម ដែលលើសពីកម្រិតដែលច្បាប់បានអនុញ្ញាត្តិទូទៅតាមច្បាប់ការងារ

.ចំនួនប្រាក់បង់ចូលបេឡាសោធន ដែលលើសពី១០% នៃប្រាក់បៀវត្សប្រចាំខែគ្មានបូកអត្ថប្រយោជន៍បន្ថែមរបស់និយោជិត

.ចំណាយសម្រាប់ការទទួលភ្ញៀវ ការកំសាន្ត ការសម្រាកលំហែ ឬការប្រើប្រាស់មធ្យោបាយណាមួយដែលទាក់ទិន នឹងសកម្មភាពទាំងនេះដែលមិនមែនជាចំណែកណាមួយនៃទំនាក់ទំនងបម្រើការងារ។

**ទាយជ្ជទានសម្រាប់ និយោជិតនិវាសនជន ដែលមានៈ**

ក. កូនស្ថិតក្នុងបន្ទុកនាពេលដែលត្រូវបង់ពន្ធត្រូវបានទទួលនូវការបន្ថយមូលដ្ឋានកំណត់ពន្ធចំនួន ១៥០,០០០រៀលក្នុងកូនម្នាក់ៗក្នុងមួយខែ។

ខ. សហព័ទ្ធដែលធ្វើតែមេផ្ទះ(ប្តី ឬប្រពន្ធ) ត្រូវបានទទួលនូវការបន្ថយមូលដ្ឋានកំណត់ពន្ធចំនួន ១៥០,០០០រៀលសម្រាប់តែម្នាក់ក្នុងមួយខែ។

គ.កូនក្នុងបន្ទុកអាយុមិនលើសពីអាយុ១៤ឆ្នាំ ឬជាសិស្ស ឬនិស្សិតដែលមានអាយុមិនលើសពី២៥ឆ្នាំ

❈ **មូលដ្ឋានគិតពន្ធ អត្រាពន្ធ**

| | | | | |
|---|---|---|---|---|
| . 0 | ⇒ | 1,500,000៛ | ⇒ | (0%) |
| . 1,500,001៛ | ⇒ | 2,000,000៛ | ⇒ | (X x 5%) – 75,000៛ |
| . 2,000,001៛ | ⇒ | 8,500,000៛ | ⇒ | (X x 10%) – 175,000៛ |
| . 8,500,001៛ | ⇒ | 12,500,000៛ | ⇒ | (X x 15%) – 600,000៛ |
| . 12,500,000៛ | ⇒ | ឡើងទៅ | ⇒ | (X x 20%) – 1,225,000៛ |

ការកំណត់ពន្ធលើប្រាក់បៀវត្សរបស់និយោជិកអនិវាសនជន សម្រាប់អ្នកជាប់ពន្ធអនិវាសនជនប្រាក់ពន្ធត្រូវកាត់ទុកដោយអ្នកបើកប្រាក់ឱ្យតាមអត្រាថេរ២០ភាគរយ លើរាល់ការទូទាត់ប្រាក់បៀវត្សជាប់ពន្ធដោយមិនមានការអនុញ្ញាត្តឱ្យដកទាយជ្ជទានសម្រាប់សហព័ន្ធជាមេផ្ទះ និងកូនក្នុងបន្ទុកទេ។

❈ **ប្រាក់បៀវត្សលើកលែងពន្ធ** (សារាចរលេខ០១១ សហវ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៦)

.សោហ៊ុយធ្វើដំណើរ និងការផ្តល់កន្លែងស្នាក់នៅក្នុងបរិវេណកន្លែងធ្វើការស្របតាមបញ្ញត្តិនៃច្បាប់ការងារ

.ប្រាក់ថ្លៃបាយដែលផ្តល់ឱ្យនិយោជិកទាំងអស់គ្មានបែងចែកតួនាទី

.មូលនិធិបេឡាសន្តិសុខសង្គម សុខមាលភាពសង្គមតាមបញ្ញត្តិច្បាប់

.ប្រាក់ធានារ៉ាប់រងសុខភាព ឬបុព្វលាភធានារ៉ាប់រងអាយុជីវិតឬសុខភាពដែលផ្តល់ឱ្យកម្មករនិយោជិតគ្រប់គ្នា

.ប្រាប់ឧបត្ថម្ភទារកដ្ឋាន ឬចំណាយទារកដ្ឋាន តាមច្បាប់ការងារ

.ប្រាក់បំណាច់បញ្ចប់កិច្ចសន្យា ឬប្រាក់បំណាច់បញ្ឈប់លែងឱ្យធ្វើការក្នុងកម្រិតដែលបានបញ្ញត្តិក្នុងច្បាប់ការងារ [9]។

**៧. ពន្ធប៉ាតង់** គឺជាពន្ធប្រចាំឆ្នាំដែលត្រូវបានកំណត់លើសកម្មភាពអាជីវកម្មដោយផ្អែកលើប្រភេទអ្នកជាប់ពន្ធ និងកម្រិតផលរបរពន្ធប៉ាតង់ត្រូវបានប្រមូលសម្រាប់ជាគុណប្រយោជន៍ថវិកាថ្នាក់ក្រោមជាតិ។

**❈ កម្រិតប្រាក់ពន្ធប៉ាតង់ត្រូវបង់**

ប្រាក់ពន្ធប៉ាតង់ត្រូវបានកំណត់ដូចខាងក្រោម៖

. អ្នកជាប់ពន្ធតូចត្រូវបង់ ៤០០ ០០០ រៀល

. អ្នកជាប់ពន្ធមធ្យមត្រូវបង់ ១ ២០០ ០០០ រៀល

. អ្នកជាប់ពន្ធធំ ត្រូវបង់៖

✓ អប្បបរមា ៣ ០០០ ០០០ រៀល

✓ អតិបរមា ៥ ០០០ ០០០ រៀល។

**❈ ការប្រកាសពន្ធ និងការជាប់ពន្ធ**

. ពន្ធប៉ាតង់ត្រូវបង់ចាប់ថ្ងៃទី០១ ខែមករា ដល់៣១ ខែមីនា ជារៀងរាល់ឆ្នាំនៅរដ្ឋបាលសារពើពន្ធ ដែលអ្នកជាប់ពន្ធមានទីកន្លែងប្រកបអាជីវកម្មពិតប្រាកដ ឬនៅធនាគារជាដៃគូរបស់អគ្គនាយកដ្ឋានពន្ធដារ

. អ្នកជាប់ពន្ធដែលចាប់ផ្តើមអាជីវកម្ម៦ខែដើមឆ្នាំ ត្រូវបង់ពន្ធប៉ាតង់ពេញ១ឆ្នាំ

. អ្នកជាប់ពន្ធដែលចាប់ផ្តើមអាជីវកម្ម៦ខែចុងឆ្នាំ ត្រូវបង់ពន្ធប៉ាតង់ពាក់កណ្តាល [10]។

**៨. ពន្ធតែមប្រើសារពើពន្ធ**( ស្លាកយីហោ និងផ្សព្វផ្សាយពាណិជ្ជកម្ម)អនុវត្តលើប័ណ្ណប្រកាសពាណិជ្ជកម្ម ស្លាកអាជីវកម្ម( យីហោ ) ផ្ទាំងអក្សរ ផ្ទាំងរូបភាព ក្នុងគោលបំណងផ្សាយពាណិជ្ជកម្ម ឬគូសភ្ជាប់នឹងមធ្យោបាយដឹកជញ្ជូននានា។ ដើម្បីជាគុណប្រយោជន៍ដល់ថវិកាថ្នាក់ជាតិ[11]។

**❈ ការលើកលែងពន្ធ**

ពន្ធលើផ្ទាំងផ្សព្វផ្សាយ ត្រូវបានលើកលែងចំពោះផ្ទាំងផ្សព្វផ្សាយក្នុងគោលបំណងមិនស្វែងរកប្រាក់ចំណេញដូចខាងក្រោម៖

-ស្លាករបស់ស្ថាប័នរដ្ឋ។

-ស្លាករបស់ស្ថានទូត ឬស្ថានកុងស៊ុលបរទេស អង្គការជាតិ និងអង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរដ្ឋាភិបាលដទៃទៀត អង្គការមិនមែនរដ្ឋាភិបាល និងសមាគមនានា។

[9] វិទ្យាស្ថាន វ៉ាន់ដា. *ច្បាប់ពន្ធដារប្រទេសកម្ពុជា* . បោះពុម្ពផ្សាយ២០២៣. ១៨៨ទំព័រ. ភ្នំពេញ។

[10] វិទ្យាស្ថាន វ៉ាន់ដា. *ច្បាប់ពន្ធដារប្រទេសកម្ពុជា*. បោះពុម្ពផ្សាយ២០២៣. ១៨៨ទំព័រ. ភ្នំពេញ។

[11] RV Accounting & Consulting. (2019, May 28). *និយមន័យពន្ធតែមប្រើសារពើពន្ធ*. Retrieved from https://www.facebook.com/share/19Ds6ksx6h/ (Accessed 14.03.25)

-ផ្ទាំងផ្សព្វផ្សាយដែលមានគោលដៅ អប់រំសង្គមជាប្រយោជន៍សាធារណៈមានជាអាទិ៍ការថែរក្សា និងការពារបរិស្ថាន ការបញ្ឈប់អំពើហិង្សាក្នុងគ្រួសារ ការការពារធនធានធម្មជាតិ ការអប់រំចរាចរណ៍ និងការអប់រំសុខភាព ។

**៩. ពន្ធលើមធ្យោបាយដឹកជញ្ជូន** និងយានជំនិះគ្រប់ប្រភេទជាពន្ធប្រចាំឆ្នាំ ដែលអនុវត្តលើមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទដោយមិនគិតថាជារបស់រដ្ឋ ឬឯកជនឡើយរួមមាន ៖

- រថយន្តដឹកទំនិញ និងរ៉ឺម៉កសណ្តោង
- រថយន្តដឹកអ្នកដំណើរ
- រថយន្តទេសចរណ៍ជលយានយន្ត ឬជលយានយន្ត ផ្លូវទន្លេ និងសមុទ្រ ។

**❈ ការលើកលែងពន្ធ**

១- រថយន្តគិលានសង្គ្រោះ រថយន្តពន្លត់អគ្គីភ័យដែលជាកម្មសិទ្ធិរបស់រដ្ឋ។

២-យានយន្តដែលជាកម្មសិទ្ធិរបស់អង្គភាពកងយោធពលខេមរភូមិន្ទកងរាជអាវុធហត្ថ និងនគរបាលជាតិ។

៣-យានយន្តដែលជាកម្មសិទ្ធិរបស់ស្ថានទូត ឬស្ថានកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលដទៃទៀត។

៤-ទោចក្រយានយន្ត និងត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រ និងគ្រឿងយន្តប្រហាក់ប្រហែល និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់១៥០ (មួយរយហាសិប)សេះ ឬតិចជាង។

**❈ មូលដ្ឋានគិតពន្ធ**

* រថយន្តដឹកទំនិញ៖ គិតលើទម្ងន់សរុប

ទម្ងន់សរុប = ទម្ងន់រថយន្ត + ទម្ងន់ផ្ទុក ( ទំនិញ + មនុស្ស )

-ចាត់ជារថយន្តដឹកទំនិញចំពោះ ក្បាលរថយន្តសណ្តោង និងសឺមីរ៉ឺម៉កសណ្តោង ត្រូវបង់ពន្ធរួមគ្នា។

-ករណីមានរ៉ឺម៉កសណ្តោងបន្ថែមទៀត ត្រូវបង់ពន្ធដោយឡែក

* រថយន្តអ្នកដំណើរ ៖ គិតលើចំនួនកៅអី
* ជលយាន ឬជលយានយន្ត ដឹកទំនិញ ៖ គិតលើទំម្ងន់ទំនិញ
* ជលយាន ឬជលយានយន្ត ដឹកអ្នកដំណើរ ៖ គិតលើប្រវែង
* ជលយាន ឬជលយានយន្ត សណ្តោង និងនេសាទ ៖ គិតលើកំលាំងម៉ាស៊ីន
* រថយន្តទេសចរណ៍ ៖ ទំហំស៊ីឡាំង និងឆ្នាំផលិត [12]។

**១០. ពន្ធប្រថាប់ត្រា** គឺជាប្រភេទពន្ធមួយដែលគិតលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិប្រើប្រាស់ក្រោមរូបភាពជាការទិញលក់ ការផ្ទេរពីម្នាក់ទៅម្នាក់ ការដោះដូរនៃចលនទ្រព្យ និងអចលនទ្រព្យ ។ អ្នកទទួលការផ្ទេរកម្មសិទ្ធិនៃទ្រព្យនោះមានកាតព្វកិច្ចត្រូវបង់ពន្ធនេះ ។

**❈ ពន្ធប្រថាប់ត្រាត្រូវបានប្រមូលចំពោះ៖**

. ការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យក្នុងក្រុមហ៊ុន

[12] វិទ្យាស្ថាន វ៉ាន់ដា. *ច្បាប់ពន្ធដារប្រទេសកម្ពុជា.* បោះពុម្ពផ្សាយ២០២៣. ១៨៨ទំព័រ. ភ្នំពេញ។

. ការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់មធ្យោបាយដឹកជញ្ជូន ឬយានយន្តគ្រប់ប្រភេទ

. ការផ្ទេរចំណែកណាមួយ ឬទាំងស្រុងនៃភាគហ៊ុនរបស់ក្រុមហ៊ុន

. កិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវាដែលប្រើប្រាស់ថវិការដ្ឋ

. លិខិតមានលក្ខណៈគតិយុត្តៈ

+លិខិតស្តីពីការបង្កើត

+ក្រុមហ៊ុនបញ្ចូលគ្នា និង

+លិខិតស្តីពីការបិទក្រុមហ៊ុន

❈ **អ្នកទទួលបន្ទុកបង់ពន្ធ**

ពន្ធប្រថាប់ត្រាត្រូវប្រមូលពីៈ

- អ្នកទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ឬមធ្យោបាយដឹកជញ្ជូន ឬយានយន្តគ្រប់ប្រភេទ
- អ្នកទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ភាគហ៊ុន
- អ្នកទទួលចុះកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវាដែលប្រើប្រាស់ថវិការដ្ឋ
- អ្នកទទួលសិទ្ធិលើលិខិតមានលក្ខណៈគតិយុត្ត ។

❈ **ការលើកលែងពន្ធ**

ការទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ដីក្នុងលក្ខណៈសម្បទានពី រាជរដ្ឋាភិបាលសម្រាប់ជាប្រយោជន៍សេដ្ឋកិច្ច ឬសង្គមកិច្ច ដីឯកជនរបស់រដ្ឋដល់ជនក្រីក្រដែលខ្វះខាតដីសម្រាប់សង់លំនៅដ្ឋាន ឬដីធ្វើ កសិឧស្សាហកម្ម ឬកសិកម្មជាលក្ខណៈគ្រួសារ។

ការទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យក្នុងរង្វង់ញាតិៈ

+ ការធ្វើសន្តតិកម្មៈ

- រវាងឪពុក-ម្តាយបង្កើត និងកូនបង្កើត រវាងប្តី និងប្រពន្ធ
- រវាងយាយ-តាបង្កើត និងចៅបង្កើត
- ពីឪពុក-ម្តាយទៅឱ្យកូនបង្កើត និងកូនប្រសារ (ទ្រព្យរួមប្តីប្រពន្ធ)។

+ ការធ្វើប្រទានកម្មលើកទី១ៈ

-រវាងឪពុក-ម្តាយបង្កើត និងកូនបង្កើត

. រវាងប្តី និងប្រពន្ធ

. រវាងយាយ-តាបង្កើត និងចៅបង្កើត

. ពីឪពុក-ម្តាយទៅឱ្យកូនបង្កើត និងកូនប្រសារ (ទ្រព្យរួមប្តីប្រពន្ធ)

. ពីយាយ-តាទៅឱ្យចៅបង្កើត និងចៅប្រសារ (ទ្រព្យរួមប្តីប្រពន្ធ)។

ការផ្ទេរកម្មសិទ្ធិទោចក្រយានយន្ត ត្រីចក្រយានយន្តគ្រប់ប្រភេទ និងត្រាក់ទ័រ និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់១៥០សេះ។

ការទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ និងមធ្យោបាយដឹកជញ្ជូន ឬយានយន្តដែលត្រូវកត់ត្រាចុះបញ្ជីសារពើភណ្ឌរបស់ស្ថាប័នរដ្ឋនានានៃព្រះរាជាណាចក្រកម្ពុជា។

ការទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ និងមធ្យោបាយដឹកជញ្ជូន ឬយានយន្តរបស់បេសកកម្មការទូត ឬកុងស៊ុលបរទេស ឬអង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការ បច្ចេកទេសរបស់រដ្ឋាភិបាលនានា។

ការទិញមធ្យោបាយដឹកជញ្ជូន ឬយានយន្តធ្វើជាទំនិញដើម្បីលក់វិញរបស់សហគ្រាសនានាដែលបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ និងបានបង់ពន្ធអាករប្រចាំខែ និងប្រចាំឆ្នាំ។ ដោយឡែក ការទិញមធ្យោបាយដឹកជញ្ជូន ឬយានយន្តដែលបានចុះបញ្ជីនៅស្ថាប័នសាធារណការ និងដឹកជញ្ជូនមិនត្រូវលើកលែងពន្ធប្រថាប់ត្រានេះទេ។

ការទទួលបានសិទ្ធិកាន់កាប់ភាគហ៊ុនរបស់អ្នកវិនិយោគមូលបត្រតាមរយៈការជួញដូរមូលបត្រ ក្នុងទីផ្សារដំបូង ឬក្នុងទីផ្សារបន្ទាប់ ការផ្ទេរភាគហ៊ុន ការទទួលសិទ្ធិកាន់កាប់ភាគហ៊ុន ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ការកែប្រែរចនាសម្ព័ន្ធភាគហ៊ុនដូចជា ការបំបែកភាគហ៊ុនរបស់ក្រុមហ៊ុនដែលមានបំណងបោះផ្សាយលក់មូលបត្រជាសាធារណៈក្រុមហ៊ុនដែលបានបោះផ្សាយលក់មូលបត្រ ជាសាធារណៈនៅក្នុងទីផ្សារដំបូង ឬនៅក្នុងទីផ្សារបន្ទាប់ ឬក្រុមហ៊ុនដែលធ្វើអាជីវកម្មពាក់ព័ន្ធក្នុង វិស័យមូលបត្រ ទោះបីតម្រូវឱ្យមានការកែប្រែលក្ខន្តិកៈក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្មក៏ដោយ ការលើកលែងពន្ធប្រថាប់ត្រានេះត្រូវមានលិខិតបញ្ជាក់ពីគណៈកម្មការមូលបត្រកម្ពុជា។ ដោយឡែកករណីដែលក្រុមហ៊ុនមិនអាចធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈបានដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អ្នកទទួលសិទ្ធិកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុនត្រូវជាប់ពន្ធប្រថាប់ត្រា និងត្រូវទូទាត់ពន្ធប្រថាប់ត្រានៃការផ្ទេរភាគហ៊ុន កន្លងមកដោយអនុលោមតាមប្រកាសនេះ លើកលែងតែមានលិខិតបញ្ជាក់ដោយឡែកពីគណៈកម្មការមូលបត្រកម្ពុជាដោយផ្អែកលើមូលហេតុសមស្របដូចជាករណីប្រធានសក្តិជាដើម។

**❈ អត្រាពន្ធ**

ក- អត្រាពន្ធ និងការកំណត់ពន្ធប្រថាប់ត្រាមានដូចខាងក្រោម៖

. ៤% នៃតម្លៃអចលនទ្រព្យចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ អចលនទ្រព្យជាសំណង់ និងដី ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យក្នុងក្រុមហ៊ុន។

. ៤% នៃតម្លៃមធ្យោបាយដឹកជញ្ជូន ឬយានយន្តចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់មធ្យោបាយ ដឹកជញ្ជូន ឬយានយន្តគ្រប់ប្រភេទ។

. ០.១% នៃតម្លៃភាគហ៊ុន ចំពោះការផ្ទេរចំណែកណាមួយ ឬទាំងស្រុងនៃភាគហ៊ុន ឬការរំលាយក្រុមហ៊ុនបញ្ចូលគ្នា។

. ០.១% នៃតម្លៃចុះកិច្ចសន្យាចំពោះកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវា ដែលប្រើប្រាស់ថវិការដ្ឋ។

១លានរៀលចំពោះលិខិតមានលក្ខណៈគតិយុត្ត៣ ប្រភេទគឺ៖

.លិខិតស្តីពីការបង្កើតក្រុមហ៊ុន

.លិខិតស្តីពីការបិទក្រុមហ៊ុន

.លិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា រួមទាំងលិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នារបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រសាធារណៈ [13]។

**១១. ពន្ធលើដីធ្លីមិនបានប្រើប្រាស់** គឺជាប្រភេទពន្ធផ្ទាល់ដែលគិតលើដីធ្លីទុកចោលទំនេរមិនប្រើប្រាស់ ។ កម្មសិទ្ធិករនៃដីធ្លីមិនបានប្រើប្រាស់នោះ ដែលជាអ្នកកាន់កាប់ និងគ្រប់គ្រងអចលនទ្រព្យនោះ ដោយមានប័ណ្ណកម្មសិទ្ធិស្របតាមបទប្បញ្ញត្តិច្បាប់មានកាតព្វកិច្ចត្រូវបង់ពន្ធនេះ ។

**❈ កម្មវត្ថុនៃពន្ធ**

- កម្មវត្ថុត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ គឺជាដីទាំងឡាយណាដែលពុំមានលក្ខណៈណាមួយនៃលក្ខណៈទាំង០៥ យ៉ាងដូចខាងក្រោម៖

១. ដីមានសំណង់ស្ថិតនៅក្នុងតំបន់លំនៅដ្ឋាន

២. ដីជួលដែលមានសំណង់មានការកាន់កាប់

៣. ដីដែលមានសកម្មភាពសេដ្ឋកិច្ចស្របតាមការកំណត់តំបន់របស់រដ្ឋ

៤. ដីជាកម្មសិទ្ធិរបស់រដ្ឋ ដែលបានជួលឱ្យទៅនីតិបុគ្គល ឬរូបវន្តបុគ្គល

៥. ដីដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងវិនិយោគ។

**❈ អត្រាពន្ធ និងមូលដ្ឋានកំណត់ពន្ធ**

. ពន្ធលើដីធ្លីមិនបានប្រើប្រាស់ត្រូវប្រមូលប្រចាំឆ្នាំតាមអត្រា២(ពីរ)ភាគរយ។

. មូលដ្ឋានគិតពន្ធលើដីធ្លីមិនបានប្រើប្រាស់ត្រូវផ្អែកលើតម្លៃដីដែលកំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់។ មូលដ្ឋានគិតពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងគណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ត្រូវកំណត់ និងបង្កើតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**❈ ការគណនាប្រាក់ពន្ធ**

.ត្រូវបានអនុញ្ញាតឱ្យកាត់ចេញពីមូលដ្ឋានកំណត់ពន្ធចំនួន១ ២០០ម៉ែត្រក្រឡាក្នុងដីមួយកន្លែង

**ប្រាក់ពន្ធត្រូវបង់** = (ផ្ទៃដីសរុប [- ១.២០០ម$^{២}$]) x មូលដ្ឋានកំណត់ពន្ធ x ២% [14]។

**(ការអនុញ្ញាតឱ្យកាត់ពីមូលដ្ឋានកំណត់ពន្ធចំនួន១២០០ម៉ែត្រក្រឡាក្នុងដីមួយកន្លែង ត្រូវបានលុបដោយមាត្រា៣ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៧ និងប្រកាសលេខ៤៥២សហវ.ប្រក.ពដ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៧)**

**១២. ពន្ធលើអចលនទ្រព្យ** គឺជាពន្ធដែលត្រូវបានកំណត់ទៅលើអចលនទ្រព្យ ដូចជា ដី ផ្ទះ អគារ និងសំណង់ផ្សេងៗជាដើម ។

**❈ ការលើកលែងពន្ធ**

១.អចលនទ្រព្យដែលជាដីធ្លីកសិកម្ម។ "ដីធ្លីកសិកម្ម" គឺជាដីស្ថិតក្នុងតំបន់ ឬប្រភេទដីកសិកម្ម ដែលកំពុងបង្កបង្កើនផលមានជាអាទិ៍ ដីស្រែដីចំការ ដីដំណាំកសិ-ឧស្សាហកម្ម ដីកសិដ្ឋានចិញ្ចឹម សត្វ វារីវប្បកម្ម ដីស្រែអំបិល។

[13] វិទ្យាស្ថាន វ៉ាន់ដា. *ច្បាប់ពន្ធដារប្រទេសកម្ពុជា* បោះពុម្ពផ្សាយ២០២៣. ១២១ទំព័រ. ភ្នំពេញ។

[14] វិទ្យាស្ថាន វ៉ាន់ដា. *ច្បាប់ពន្ធដារប្រទេសកម្ពុជា*. បោះពុម្ពផ្សាយ២០២៣. ១២១ទំព័រ. ភ្នំពេញ។

ក្នុងករណីអចលនទ្រព្យ ឬចំណែកណាមួយនៃអចលនទ្រព្យ ដែលស្ថិតនៅក្រៅតំបន់ ឬប្រភេទដីកសិកម្ម (តំបន់លំនៅដ្ឋាន តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម) ដែលកំពុងបង្កបង្កើនផលកសិកម្មក្រោមរូបភាព ដូចខាងក្រោមត្រូវបានលើកលែងពន្ធលើអចលនទ្រព្យ៖

- ចិញ្ចឹមសត្វ ត្រូវមានលិខិតអនុញ្ញាតពីមន្ទីរកសិកម្ម
- វារីវប្បកម្ម ត្រូវមានលិខិតអនុញ្ញាតពីរដ្ឋបាលជលផល
- ក្រៅពីការចិញ្ចឹមសត្វ និងវារីវប្បកម្មត្រូវមានលិខិតបញ្ជាក់ពីខណ្ឌ/ស្រុក/ ក្រុង។

២. អចលនទ្រព្យជាកម្មសិទ្ធិរបស់៖

រាជរដ្ឋាភិបាល ឬស្ថាប័នរដ្ឋ ដូចជា៖ សាលារៀន មន្ទីរពេទ្យ ក្រសួង មន្ទីរ ស្ថាប័ន... ដែលបានចុះបញ្ជីសារពើភណ្ឌជាទ្រព្យសម្បត្តិរដ្ឋ។

ក្នុងករណី អចលនទ្រព្យដែលកត់ត្រាជាទ្រព្យសកម្មធ្វើអាជីវកម្មរបស់សហគ្រាសសាធារណៈ ឬក្រុមហ៊ុនចម្រុះរដ្ឋ អចលនទ្រព្យនោះ មិនត្រូវបានលើកលែងពន្ធលើអចលនទ្រព្យទេ។ ចំពោះដីរដ្ឋដែលរាជរដ្ឋាភិបាលបានជួលឱ្យឯកជនសាងសង់សំណង់សម្រាប់ធ្វើអាជីវកម្ម ដីនោះត្រូវបានលើកលែងពន្ធលើអចលនទ្រព្យប៉ុន្តែសំណង់ត្រូវជាប់ពន្ធ។

៣. អចលនទ្រព្យដែលកម្មសិទ្ធិរបស់សហគមន៍ ឬបុគ្គលណាមួយដែល៖

- ត្រូវបានរៀបចំឡើង និងដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា និងសប្បុរសធម៌
- គ្មានចំណែកណាមួយនៃអចលនទ្រព្យ ឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាប្រយោជន៍ឯកជន។ការលើកលែងពន្ធនេះមិនរាប់បញ្ចូលទេ ចំពោះអចលនទ្រព្យ៖
- ដែលត្រូវបានជួល ឬផ្តល់ឱ្យបណ្តោះអាសន្ន សម្រាប់គោលដៅសុទ្ធសាធខាងសាសនា និងសប្បុរសធម៌
- ជាកម្មសិទ្ធិរបស់អង្គការសាសនា ឬអង្គការសប្បុរសធម៌ដែលបានជួល ឬផ្តល់ជាបណ្តោះអាសន្ន ឱ្យសហគមន៍ ឬបុគ្គលណាមួយដែលប្រើប្រាស់អចលនទ្រព្យនោះក្រៅពីគោលដៅសាសនា និង សប្បុរសធម៌។

៤. អចលនទ្រព្យជាកម្មសិទ្ធិរបស់៖

- បេសកកម្មការទូត ឬកុងស៊ុលបរទេស
- អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស របស់រដ្ឋាភិបាលនានា ដែលទទួលស្គាល់ដោយរាជរដ្ឋាភិបាល។

ការលើកលែងពន្ធនេះមិនរាប់បញ្ចូលទេ ចំពោះអចលនទ្រព្យជាកម្មសិទ្ធិរបស់៖

- ឯកជនជួលឱ្យបេសកកម្មការទូតកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រាជរដ្ឋាភិបាល
- បេសកកម្មការទូត កុងស៊ុលបរទេស... ជួលឱ្យអតិថិជន។

៥. អចលនទ្រព្យដែលជាហេដ្ឋារចនាសម្ព័ន្ធរួមមាន ផ្លូវ ស្ពាន ប្រព័ន្ធផលិតទឹកស្អាត ឬផលិតអគ្គិសនី ព្រលានយន្តហោះ កំពង់ផែ រួមបញ្ចូលទាំងអគារ និងការិយាល័យដែលបម្រើផ្ទាល់ ដល់សកម្មភាពនៃហេដ្ឋារចនាសម្ព័ន្ធទាំងនេះ។

៦. ផ្ទះ អគារ និងសំណង់ផ្សេងៗ ដែលសាងសង់លើដីធ្លីកសិកម្មដែលបម្រើផ្ទាល់ និងជាអចិន្ត្រៃយ៍ ដល់សកម្មភាពកសិកម្ម។

៧. អចលនទ្រព្យទទួលរងនូវការខូចខាតធ្ងន់ធ្ងរ ដោយករណីប្រធានសក្តិដូចជា គ្រោះធម្មជាតិ (ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយដី) សង្គ្រាម កុប្បកម្ម អគ្គីភ័យ ឬគ្រោះមហន្តរាយជាយថាហេតុ។

៨. ផ្ទះ អគារ និងសំណង់ដែលកំពុងត្រូវបានសាងសង់តិចជាង៨០% និងមិនទាន់បានប្រើប្រាស់។ ប៉ុន្តែដីត្រូវជាប់ពន្ធលើអចលនទ្រព្យ។

៩. អចលនទ្រព្យក្នុងតំបន់សេដ្ឋកិច្ចពិសេសដែលបម្រើផ្ទាល់ដល់សកម្មភាព ផលិតកម្ម ឬសេវាកម្ម។

**(ប្រកាសលេខ៨៩៣ សហវ.ប្រក និងសារាចរណ៍ណែនាំលេខ០១៥ សហវ.អពដ)**

**❈ មូលដ្ឋានគិតពន្ធ និងតម្លៃអចលនទ្រព្យ អត្រា**

<u>អត្រាពន្ធ</u>

មូលដ្ឋានគិតពន្ធ និងតម្លៃអចលនទ្រព្យ អត្រាពន្ធ ពន្ធលើអចលនទ្រព្យត្រូវប្រមូលប្រចាំឆ្នាំតាមអត្រា ០.១% នៃមូលដ្ឋានគិតពន្ធ។

<u>មូលដ្ឋានគិតពន្ធ</u>

មូលដ្ឋានគិតពន្ធសម្រាប់ពន្ធលើអចលនទ្រព្យ គឺជាតម្លៃ៨០% នៃតម្លៃអចលនទ្រព្យដែលត្រូវអនុញ្ញាត ឱ្យកាត់បន្ថយនូវទឹកប្រាក់១០០ លានរៀល។

<u>តម្លៃអចលនទ្រព្យ</u>

តម្លៃអចលនទ្រព្យ គឺត្រូវកំណត់ដោយ គណៈកម្មការវាយតម្លៃអចលនទ្រព្យ ដោយយោងតាមតម្លៃទីផ្សារ

<u>ការគណនាប្រាក់ពន្ធលើអចលនទ្រព្យ</u>

មូលដ្ឋានគិតពន្ធ = (តម្លៃអចលនទ្រព្យ x ៨០%) - ១០០ ០០០ ០០០៛

ប្រាក់ពន្ធត្រូវបង់ = មូលដ្ឋានគិតពន្ធ x ០.១%

ប្រាក់ពន្ធត្រូវបង់ = មូលដ្ឋានគិតពន្ធ x ០.១% [15]។

**១៣. ពន្ធលើចំណេញមូលធន** គឺជាពន្ធដែលសម្រេចបានពីការលក់ ឬផ្ទេរមូលធន នៅព្រះរាជាណាចក្រកម្ពុជា និងនៅបរទេសដោយអ្នកជាប់ពន្ធនិវាសនជនជារូបវន្តបុគ្គល និងពីការលក់ ឬផ្ទេរមូលធននៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយអ្នកជាប់ពន្ធអនិវាសនជន [16]។

**អាករួមមាន៖**

**១. អាករពិសេសលើទំនិញ និងសេវាមួយចំនួន** គឺជាអាករដែលអនុវត្តលើទំនិញ ឬសេវាមួយចំនួនដែលមានលក្ខណៈប្រណិត ឬមិនមែនជាតម្រូវការចាំបាច់ក្នុងជីវភាពប្រចាំថ្ងៃ ឬប៉ះពាល់ដល់សុខភាព សង្គម ឬបរិស្ថាន [17]។

**២. អាករបំភ្លឺសាធារណៈ** គឺជាអាករដែលអនុវត្តចំពោះការផ្គត់ផ្គង់ផលិតផលសុរាមេរ័យ ឬបារី បន្ទាប់ពីបាននាំចូល ឬផលិតក្នុងព្រះរាជាណាចក្រកម្ពុជា។

អាករសម្រាប់បំភ្លឺសាធារណៈត្រូវបានលើកលែងចំពោះ៖

[15] វិទ្យាស្ថាន វ៉ាន់ដា. *ច្បាប់ពន្ធដារប្រទេសកម្ពុជា*. បោះពុម្ពផ្សាយ២០២៣. ១២១ទំព័រ. ភ្នំពេញ។

[16] វិទ្យាស្ថាន វ៉ាន់ដា. *ច្បាប់ពន្ធដារប្រទេសកម្ពុជា*. បោះពុម្ពផ្សាយ២០២៣. ១២១ទំព័រ. ភ្នំពេញ។

[17] វិទ្យាស្ថាន វ៉ាន់ដា. *ច្បាប់ពន្ធដារប្រទេសកម្ពុជា*. បោះពុម្ពផ្សាយ២០២៣. ១២១ទំព័រ. ភ្នំពេញ។

- ស្រា ដែលផលិតលក្ខណៈគ្រួសារ
- ទឹកត្នោតជូរ
- ថ្នាំជក់ វត្ថុធាតុដើម [18]។

**៣. អាករលើតម្លៃបន្ថែម** គឺជាប្រភេទពន្ធប្រយោលដែលរដ្ឋដកហូតពីអ្នកប្រើប្រាស់ចុងក្រោយ តាមរយៈអ្នកផ្គត់ផ្គង់ដែលជាបុគ្គលជាប់អាករ [19]។

**៤. អាករលើការស្នាក់នៅ** គឺជាអាករដែលត្រូវបានកំណត់ និងប្រមូលលើការស្នាក់នៅក្នុងសណ្ឋាគារដែលជាប់ពន្ធក្នុងរបបស្វ័យប្រកាស សម្រាប់ជាគុណប្រយោជន៍ថវិកាថ្នាក់ក្រោមជាតិ [20]។

### ២.១.៤ សារៈសំខាន់នៃពន្ធ

ពន្ធផ្តល់ប្រយោជន៍ចំពោះខ្លួនឯង និងសង្គមជាតិមានដូចជា ៖

- បើកប្រាក់បៀវត្សជូនមន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ មន្ត្រី កម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងនិវត្តន៍ជន ។
- ពន្ធជាប្រភពចំណូលដ៏សំខាន់ដើម្បីទ្រទ្រង់ និងដំណើរការរដ្ឋទាំងមូល ៖ ពន្ធដែលប្រមូលបានគឺសម្រាប់ចំណាយទៅលើ គ្រឿងឧបករណ៍ គ្រឿងសង្ហារឹម សម្ភារៈការិយាល័យនៅតាមក្រសួង មន្ទីរ ស្ថាប័ន និងអង្គភាពចំណុះឱ្យរដ្ឋ ។
- ប្រាក់ពន្ធដែលប្រមូលបាន គឺសម្រាប់ចំណាយទៅលើហេដ្ឋារចនាសម្ព័ន្ធសង្គម ដូចជា ៖ ផ្លូវថ្នល់ ស្ពាន សាលារៀន មន្ទីរពេទ្យ ជាដើម ។
- ចំណាយទៅលើវិស័យអប់រំ និងសុខាភិបាល ៖ ការសិក្សាអប់រំចំណេះដឹងទូទៅដោយមិនបង់ប្រាក់ ព្យាបាលនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យរដ្ឋ ។
- ប្រាក់ពន្ធ ក៏ត្រូវបានចំណាយទៅលើ វិស័យសន្តិសុខសណ្តាប់ធ្នាប់សង្គម និងវិស័យការពារជាតិ [21]។

## ២.២ នីតិវិធីក្នុងការទប់ស្កាត់បទល្មើសរបស់អ្នកជាប់ពន្ធ

### ២.២.១ និយមន័យនីតិវិធី

**នីតិ** គឺជាវិធានទាំងឡាយដែលគ្រប់គ្រងជីវភាពរស់នៅក្នុងសង្គម ដោយមានការដាក់ទណ្ឌកម្មពីអំណាចសាធារណៈ[22]។

**នីតិ** គឺជាវិទ្យាសាស្ត្រច្បាប់សិក្សាលើសំណុំវិធានទាំងឡាយណាដែលមនុស្សជាអ្នកបង្កើតឡើងដើម្បីគ្រប់គ្រងការរស់នៅ និងគ្រប់គ្រងការទំនាក់ទំនងរបស់មនុស្សក្នុងសង្គមតាមរយៈការអនុវត្ត និងផ្តន្ទាទោស ដាក់ទណ្ឌកម្មដោយអំណាចសាធារណៈ ។ លើសពីនេះទៅទៀត នីតិជាមធ្យោបាយដោះស្រាយទំនាស់ក្នុងសង្គម។

### ២.២.២ ប្រវត្តិនីតិវិធី

---

[18] វិទ្យាស្ថាន វ៉ាន់ដា. *ច្បាប់ពន្ធដារប្រទេសកម្ពុជា.* បោះពុម្ពផ្សាយ២០២៣. ១៨៨ទំព័រ. ភ្នំពេញ។

[19] វិទ្យាស្ថាន វ៉ាន់ដា. (២០២២). *គណនេយ្យអនុវត្តន៍ និងពន្ធ.* បោះពុម្ពផ្សាយលើកទី៣. ១៩០ទំព័រ

[20] វិទ្យាស្ថាន វ៉ាន់ដា.*ច្បាប់ពន្ធដារប្រទេសកម្ពុជា.* បោះពុម្ពផ្សាយ២០២៣. ១២១ទំព័រ. ភ្នំពេញ។

[21] KHsearch .(2020, March 05) *តើពន្ធផ្តល់ផលប្រយោជន៍អ្វីខ្លះចំពោះខ្លួនឯង និងសង្គមជាតិ*. Retireved from https://www.khsearch.com/qna/29955 (Accessed 14.03.25)

[22] វិទ្យាស្ថាន វ៉ាន់ដា. (ឆ្នាំ២០២២) *សេចក្តីផ្តើមនៃនីតិ.* បោះពុម្ពផ្សាយលើកទី៩.១០១ទំព័រ. ភ្នំពេញ។

នៅសម័យសង្គមបុព្វកាលមនុស្សរស់នៅដោយគ្មានច្បាប់អ្វីទាំងអស់ទេ ប៉ុន្តែមនុស្សអាចរស់នៅជាមួយគ្នាបាន ហើយថែមទាំងមានការគោរពគ្នាទៅវិញទៅមកទៀតផង។ ការរស់នៅរបៀបនេះ គឺជាការរស់នៅតាមរយៈការគោរពនូវទំនៀមទម្លាប់ប្រពៃណី និងសាសនាជាដើម។ ប៉ុន្តែក្នុងពេលខ្លះ ក៏មានការរំលោភបំពាន ការធ្វើបាប ការជិះជាន់ ការកេងប្រវ័ញ្ច និងការជំទាស់ប្រឆាំងគ្នាជានិរន្តរ៍ផងដែរ។ ទង្វើបែបនេះធ្វើឱ្យមនុស្សយល់ថាគួរតែរៀបចំឱ្យមាននូវឆន្ទៈរួមមួយ។ ឆន្ទៈរួមនេះធ្វើឱ្យការរស់នៅរបស់មនុស្សតាមទម្លាប់ខាងលើមានការវិវត្តន៍ទៅជាការរៀបចំក្បួនខ្នាតមួយចំនួន ដើម្បីជាការរក្សាទុកក៏ដូចជាការបន្តការគោរពនូវទំនៀមទម្លាប់ ប្រពៃណីខាងលើនាពេលក្រោយៗ ទៀត។

ភស្តុតាងជាក់ស្តែងជាច្រើនបានបង្ហាញឱ្យឃើញថា ច្បាប់បានចាប់កកើតឡើងតាំងពីយូរយារណាស់មកហើយ ពោលគឺតាំងពីសម័យដើមមកម្លេះ គឺតាំងពីសម័យកាលដែលមនុស្សចេះរួបរួមគ្នា រស់នៅជាក្រុម ជាពួកជាកុលសម្ព័ន្ធ ដោយត្រូវមានមេក្រុម មេពួក ឬមេកន្ទ្រាញ (ស្តេចក្រាញ់) ។ មេក្រុម មេពួក មេកន្ទ្រាញ តែងតែរិះរកគំនិត និងវិធានផ្សេងៗ ដើម្បីធ្វើការគ្រប់គ្រងកូនចៅរបស់ខ្លួន។ ការគ្រប់គ្រងនេះហើយ ដែលជាការចាប់ផ្តើមកកើតនូវច្បាប់មួយដែលមេក្រុម មេពួក ឬមេកន្ទ្រាញខ្លះ គ្រប់គ្រងតាមបែបផ្តាច់ការ និងខ្លះទៀតមិនផ្តាច់ការ។ រហូតដល់មានជាការគ្រប់គ្រងដោយព្រះរាជា ដែលព្រះរាជាធ្វើការគ្រប់គ្រងនគរ ការពារអំណាច ការពារតំណែង និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជារាស្ត្របាន។ ទាំងនេះ គឺជាការបញ្ជាក់អំពីភាពរីកចម្រើននៃកំណើតរបស់ច្បាប់។

យ៉ាងណាមិញប្រទេសកម្ពុជា យើងអាចសង្កេតឃើញថា តើមានការលំបាកយ៉ាងណាខ្លះ ក្នុងបេសកកម្មកសាងប្រាសាទអង្គរវត្ត។ ជាការពិតណាស់ក្នុងដំណើរការកសាងនេះ គឺពិតជាមានការ លំបាកយ៉ាងខ្លាំងទាំងបច្ចេកទេស ធនធានមនុស្ស និងការគ្រប់គ្រង ពិសេសគឺការសាងសង់។ ដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ គឺត្រូវទាមទារឱ្យមាននូវច្បាប់នៃការគ្រប់គ្រងសង្គមមួយដ៏មានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។

ដូច្នេះយើងអាចនិយាយជារួមបានថាច្បាប់ គឺពិតជាមានតាំងពីយូរយារណាស់មកហើយគ្រាន់តែយើងមិនមានឯកសារបញ្ជាក់ច្បាស់លាស់តែប៉ុណ្ណោះ ប៉ុន្តែយើងអាចមើលទៅលើភស្តុតាងមួយចំនួនដែលបន្សល់ទុកដូចជា ប្រាសាទអង្គរវត្ត មហាកំពែងចិន...។ ដែលសុទ្ធតែជាភស្តុតាង បញ្ជាក់អំពីការកកើតច្បាប់។

នីតិត្រូវបានមនុស្សស្ទើរតែគ្រប់រូបប្រើប្រាស់ជារៀងរាល់ថ្ងៃ ប៉ុន្តែមនុស្សដែលបាននឹងកំពុងប្រើប្រាស់នីតិនោះភាគច្រើនមិនបានដឹងថាខ្លួនកំពុងប្រើប្រាស់នីតិឡើយ។ តាមពិតទៅការទិញនូវសារព័ត៌មាន ០១ ច្បាប់ ឬសៀវភៅ ០១ ក្បាល ឬសម្លៀកបំពាក់ ០១កំប្លែរ ឬចំណីអាហារផ្សេងៗ សុទ្ធសឹងតែស្ថិតក្នុងវិស័យនៃនីតិទាំងអស់។ សូម្បីនៅពេលនគរបាលបញ្ឈប់បុគ្គលម្នាក់ដែលកំពុងបើកបរល្បឿនហួសកំណត់ ឬមិនគោរពច្បាប់ចរាចរណ៍ ក៏ស្ថិតក្នុងវិស័យនៃនីតិដែរ។

នីតិវាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងសីលធម៌ក៏ដូចជាសាសនា។ ឧទាហរណ៍ ៖ នីតិដាក់ទណ្ឌកម្មលើអំពើមនុស្សឃាត និងដាក់បញ្ញត្តិនូវរាល់វិធានផ្សេងៗ ដើម្បីចៀសវាងនូវការប៉ះពាល់ដល់អាយុជីវិតមនុស្ស។ ចំណែកសីលធម៌ និងសាសនាក៏បង្ហាញឱ្យឃើញថា ការសម្លាប់មនុស្ស(មនុស្សឃាត ជារឿងមិនគប្បីទាល់តែសោះ ព្រោះថាបើយើងចង់រស់មានសេចក្តីសុខអ្នកដទៃក៏ចង់រស់មានសេចក្តីសុខដូចយើងដែរ ហើយសីលធម៌ និងសាសនាសុទ្ធតែអប់រំមនុស្សក្នុងគោលបំណងឱ្យមនុស្សអាចរួមរស់នៅជាមួយគ្នា ក្នុងសង្គមមួយបាន។

នីតិមានលក្ខណៈពិសេសខុសពីប្រពៃណីទំនៀមទម្លាប់ សីលធម៌ និងសាសនាត្រង់ថា នីតិត្រូវបានធានាការអនុវត្ត និងចាប់បង្ខំដោយអំណាចសាធារណៈ(អំណាចរដ្ឋ)។ចំណែកប្រពៃណីទំនៀមទម្លាប់សីលធម៌ និងសាសនា គឺមិនមានការចាប់បង្ខំឱ្យអនុវត្តដោយអំណាចរដ្ឋទេ គឺពាក់ព័ន្ធទៅនឹងជំនឿសាសនារបស់បុគ្គល ឬគ្រួសារតែប៉ុណ្ណោះ។

នីតិមានមុខងារធ្វើឱ្យមានរបៀបរៀបរយក្នុងជីវភាពសង្គម និងការប្រាស្រ័យទាក់ទងគ្នារវាងមនុស្ស និងមនុស្ស។ នីតិកំណត់ព្រំដែននៃអំណាច និងអំពើនៃអ្នកដឹកនាំ ហើយរាំងមិនឱ្យមនុស្សធ្វើអ្វីតាមទំនើងចិត្ត (នីតិក៏មានបំណងការពារអ្នកដែលគ្មានអំណាច)។

**២.២.៣ ទ្រឹស្តីនីតិវិធី**

**១.ចំណាត់ថ្នាក់នីតិ**

តាមលោក Cicéron (106-43 មុនគ.ស) ជនជាតិរ៉ូម៉ាំងគាត់បានបែងចែកច្បាប់ជា៣ប្រភេទគឺ៖

- នីតិធម្មជាតិ
- នីតិវិជ្ជមាន
- នីតិប្រជាជាតិ ឬនីតិអន្តរជាតិ[23]។

**២.ការបែងចែកជានីតិជាតិ និងនីតិអន្តរជាតិ**

នីតិជាតិ គឺជាច្បាប់សម្រាប់គ្រប់គ្រងរដ្ឋនីមួយៗ ហើយមានអនុភាពអនុវត្តតែនៅលើផែនដី ឬរដ្ឋនោះតែប៉ុណ្ណោះ។

នីតិអន្តរជាតិ គឺជាច្បាប់សម្រាប់គ្រប់គ្រងទំនាក់ទំនងរដ្ឋ និងរដ្ឋ ឬរវាងរដ្ឋ និងអង្គការអន្តរជាតិ។ ក្នុងក្របខណ្ឌអន្តរជាតិគេត្រូវ បង្កើតច្បាប់ថ្មីតាមរយៈការចរចារវាង រដ្ឋ និងរដ្ឋ ព្រោះរដ្ឋមានអធិបតេយ្យរៀងៗខ្លួនមិនចំណុះក្រោមច្បាប់ជាតិណាមួយឡើង។

**៣.នីតិសាធារណៈ និងនីតិឯកជន**

នីតិសាធារណៈ៖ គឺជានីតិដែលគ្រប់គ្រងទំនាក់ទំនងរវាងអំណាចរដ្ឋ និងបុគ្គលឯកជន។

នីតិឯកជន៖ គឺជានីតិដែលគ្រប់គ្រងទំនាក់ទំនងរវាងបុគ្គលឯកជន និងបុគ្គលឯកជន។

**៤.នីតិវត្ថុវិស័យ និងនីតិអត្តវិស័យ**

-នីតិវត្ថុវិស័យ (Droit objectif/objective law): គឺជាវិធានទាំងឡាយដែលគ្រប់គ្រងជីវភាពរស់នៅក្នុងសង្គមដែលមានការដាក់ទណ្ឌកម្មពីអាជ្ញាធរសាធារណៈ។

-នីតិអត្តវិស័យ(Droit subjecti/Subjective Law): គឺជាបុព្វសិទ្ធិដែលច្បាប់ទទួលស្គាល់ចំពោះបុគ្គលសម្រាប់ប្រើប្រាស់ជាប្រយោជន៍ផ្ទាល់ខ្លួនព្រមទាំងទទួលបានការពារពីច្បាប់។

**២.២.៤ តួនាទីរបស់នីតិវិធី**

+ចំពោះមនុស្ស និងមនុស្ស

-ទប់ស្កាត់ជម្លោះ

-ដោះស្រាយជម្លោះ

- ផ្តល់នូវយុត្តិធម៌

[23] វិទ្យាស្ថាន វ៉ាន់ដា. (ឆ្នាំ២០២២). *សេចក្តីផ្តើមនៃនីតិ*. បោះពុម្ពផ្សាយលើកទី៩. ១០១ទំព័រ. ភ្នំពេញ

- ការពារមនុស្ស សេរីភាព និងទ្រព្យ

+ចំពោះរាស្ត្រ និងរដ្ឋ

- កំណត់អំណាចរបស់រដ្ឋ

- កំណត់សេរីភាពរបស់បុគ្គល

- ផ្តល់ដំណោះស្រាយនៃជំនួសរវាងរាស្ត្រ និងរដ្ឋ ការពារសង្គមមនុស្ស និងពូជមនុស្ស។

## ២.៣ គោលការណ៍ដើម្បីកំណត់បទល្មើសអ្នកជាប់ពន្ធ

### ២.៣.១ និយមន័យអ្នកជាប់ពន្ធ

អ្នកជាប់ពន្ធ៖

- វាក្យសព្ទ អ្នកជាប់ពន្ធ ឬអ្នកបង់ពន្ធសំដៅលើរូបវន្តបុគ្គល ឬអង្គភាពអាជីវកម្ម/នីតិបុគ្គល ដែលមានកាតព្វកិច្ចបង់ពន្ធជូនរដ្ឋ[24]។
- នៅក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារនៃព្រះរាជាណាចក្រកម្ពុជាមានចែងថា អ្នកជាប់ពន្ធគឺជាបុគ្គលទាំងឡាយដែលមានកាតព្វកិច្ចត្រូវបង់ពន្ធ។

### ២.៣.២ ប្រវត្តិអ្នកជាប់ពន្ធ

មុនឆ្នាំ២០១៦ យោងតាមមាត្រា៤ នៃ ច.ស.ព បានចែងរបបកំណត់ពន្ធជា៣ គឺ៖

១. របបស្វ័យប្រកាស (របបពិត)

២. របបបំព្រួញ

៣. របបម៉ៅការ

សម្រាប់ពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជាអនុវត្តរបបកំណត់ពន្ធ ស្វ័យប្រកាស។

អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស គឺជានីតិបុគ្គលទាំងឡាយដែលបានចុះបញ្ជីពាណិជ្ជកម្មនៅកម្ពុជា និងបុគ្គលទាំងឡាយដែលប្រកបធុរៈកិច្ចដែលមានផលរបរប្រចាំឆ្នាំ ៖

- ចាប់ពី ៥០០ លានរៀលឡើងទៅ សម្រាប់ការផ្គត់ផ្គង់ទំនិញ
- ចាប់ពី ២៥០ លានរៀលឡើងទៅ សម្រាប់ការផ្គត់ផ្គង់សេវា
- ចាប់ពី១២៥ លានរៀលឡើងទៅ សម្រាប់ការធ្វើកិច្ចសន្យាជាមួយរដ្ឋ[25]។

អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ ត្រូវមានកាតព្វកិច្ចរៀបចំបញ្ជីកាគណនេយ្យ (បិទបញ្ជីគណនេយ្យ ) របស់ខ្លួន និងរៀបចំដាក់លិខិតប្រកាសតាមគំរូទម្រង់លិខិតប្រកាសសារពើពន្ធ។ បច្ចុប្បន្ននេះការដាក់លិខិតប្រកាសមាន២វិធី៖ ១.ការដាក់លិខិតប្រកាស និងការដាក់ទម្រង់បង់ប្រាក់ P101 ដោយផ្ទាល់ (ដោយសារតែក្រុមហ៊ុនខ្លះមិនទាន់ធ្វើបច្ចុប្បន្នភាព)។ ២.ការប្រកាសតាម E-filling ។ បើនិយាយទៅលើការប្រកាសពន្ធតាម E-filling វាមានភាពងាយស្រួលច្រើនជាងការដាក់លិខិតប្រកាសពន្ធផ្ទាល់ទាំងការបញ្ចូលបញ្ជីទិញ-លក់ ព័ត៌មានប្រកាសពន្ធកាត់ទុក ពន្ធលើប្រាក់បៀវត្ស និងអត្ថប្រយោជន៍បន្ថែមជាដើម ដែលធ្វើឱ្យអ្នកជាប់ពន្ធចំណេញពេលវេលាច្រើន។

---

[24] សាកលវិទ្យាល័យវ៉ាន់ដា. *ច្បាប់ពន្ធដារប្រទេសកម្ពុជា*. បោះពុម្ពផ្សាយ២០២៣. ១៨៨ទំព័រ

[25] KHSEARCH. (2019.04.11). *ដូចម្ដេចហៅថារបបស្វ័យប្រកាស(របបពិត)*: https://www.khsearch.com/qna/18607

នៅចុងឆ្នាំ២០០៨មានអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសមានចំនួន១២,០៨៩សហគ្រាស ក្នុងនោះមានសហគ្រាសអ្នកជាប់ពន្ធធំចំនួន១,១៧១សហគ្រាសនៅទូទាំងប្រទេស និងអ្នកជាប់ពន្ធមធ្យមចំនួន៩,១៤៤ សហគ្រាសនៅភ្នំពេញ១,៧៧៤នៅតាមខេត្ត-ក្រុងទាំង២៤ ។ ចំណូលដែលទទួលបានពីអ្នកជាប់ពន្ធទាំងនេះមានប្រមាណ៨៥% នៃចំណូលពន្ធដារសរុប ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន[26]។

អ្នកជាប់ពន្ធតាមរបបម៉ៅការ គឺជាអ្នកជាប់ពន្ធតូច ដែលស្ថិតនៅក្រោមកំរិតអប្បបរមាដែលត្រូវចុះបញ្ជីជាអ្នកជាប់ពន្ធតាម របបស្វ័យប្រកាស និងត្រូវបានកំណត់ឱ្យបង់ប្រាក់ពន្ធក្នុងរយៈពេលកំណត់ណាមួយ បីខែ ឬប្រាំមួយខែនៃឆ្នាំប្រតិទិន។ នៅក្នុងរបបនេះមានសហគ្រាសតាមរបបម៉ៅការប្រមាណ១៥% នៃចំណូលពន្ធដែលអគ្គនាយកដ្ឋានពន្ធដារ រៀបចំមូលដ្ឋានត្រូវបង់ពន្ធស្របតាមបញ្ជីទាំងឡាយដែលប្រគល់មកដោយការប៉ាន់ប្រមាណជាក់ស្តែងណាស់ដែលថាប្រព័ន្ធនេះនឹងត្រូវចំណាយច្រើន ដើម្បីគ្រប់គ្រងឱ្យបានប្រសើរឡើង។ ចំពោះរបបបំពេញ គេមិនទាន់បានអនុវត្តន៍ទេ។

សម្រាប់ពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជាអនុវត្តរបបកំណត់ពន្ធ ស្វ័យប្រកាស(របបពិត)តែមួយគត់។

**២.៣.៣ ទ្រឹស្តីអ្នកជាប់ពន្ធ**

ស្មីត (Adam Smith) បានកំណត់ពន្ធដែលគាត់ទារពន្ធលើផលិតផលទំនើបៗ និងពន្ធលើការជួលដែលជាតម្រូវការរបស់ប្រទេស។ គាត់រំពឹងថាច្បាប់លើការយកពន្ធនេះនឹងត្រូវគ្មានភាពពុករលួយហើយបុគ្គលម្នាក់ៗត្រូវតែបង់នូវចំនួនដែលរដ្ឋកំណត់ដោយគ្មានការអន្តរាគមន៍។ ការទារពន្ធគឺ ធ្វើយ៉ាងណាឱ្យអ្នកបង់មានការពេញចិត្តនឹងបង់។ គាត់បាននិយាយថា "ពន្ធដែលបុគ្គលគ្រប់រូប បានបង់សម្គាងថា មិនមែនជាការបង្ខិតបង្ខំតែជាសេរីភាព" [27]។

[26] WordPress. DY CHANDOEUN. *ទ្រឹស្តីអ្នកជាប់ពន្ធ*. Retrieved from https://lorkremlaw.wordpress.com (Accessed 14.03.25)

[27] HR and Training Solution. (2020, March 06). *ទ្រឹស្តីអ្នកជាប់ពន្ធ*. Retrieved from https://m.facebook.com (Accessed 14.03.25)

# ជំពូកទី៣

# នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធរបស់ អគ្គនាយកដ្ឋានពន្ធដារ

## ៣.១ ស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ

### ៣.១.១ ប្រវត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ



ប្រព័ន្ធពន្ធដារត្រូវលុបបំបាត់ចោលនៅក្នុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដោយសារមានការកើតមានឡើងនូវសង្គ្រាម (របបខ្មែរក្រហម ឬរបបប៉ុលពត) និងបានធ្វើឱ្យប្រជាជនជួបនូវភាពលំបាក ការបាត់បង់ជីវិតជាច្រើននាក់ផងដែរ។ ប្រព័ន្ធពន្ធដារត្រូវបានបង្កើតឡើងវិញដំបូងនៅឆ្នាំ១៩៨២ ដែលបានអនុវត្តឡើងនៅរាជធានីភ្នំពេញ និងខេត្តចំនួន១០ផ្សេងទៀតដែលគេហៅថា របបម៉ោការហើយបានគ្រប់គ្រងដោយនាយកដ្ឋានពន្ធដារ។ លើសពីនេះទៅទៀត នាយកដ្ឋានពន្ធដារបានបង្កើតពន្ធមួយចំនួនផ្សេងទៀតដើម្បី អនុវត្ត និងមានការចែកច្បាប់ និងមាត្រាយ៉ាងច្បាស់លាស់។

• ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៩ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១.៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ចែងអំពីការអនុញ្ញាតឱ្យប្រមូលអាករបំភ្លឺសាធារណៈលើតម្លៃសុរាមេរ័យ និងបារី ដែលជាផលិតផលមកពីបរទេស។

• ពន្ធប៉ាតង់  ត្រូវបានអនុលោមតាមខ្លឹមសារក្រឹត្យច្បាប់លេខ២២ ក្រ.ច ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៤ ស្តីពីពន្ធប៉ាតង់ និងមាត្រា៣៩ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែល ប្រកាសដោយព្រះរាជក្រម លេខ ១១ ន.ស៩៤ ចុះថ្ងៃទី៣១ ខែធ្នូ  ឆ្នាំ១៩៩៤ និងបទប្បញ្ញត្តិស្តីពីសារពើពន្ធ។

• ពន្ធលើប្រាក់បៀវត្ស ចាប់ផ្តើមដំបូង គឺចេញពីព្រះរាជក្រមលេខ ១១ ន.ស ៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ (ច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ ១៩៩៥) តែត្រូវបានធ្វើវិសោធនកម្មដ៏ធំនៅឆ្នាំ១៩៩៧។

• ពន្ធលើកាត់ទុក  ចាប់ផ្តើម គឺចេញពីព្រះរាជក្រមលេខ នស.រកម. ០២៩៧ ថ្ងៃទី២៤  ខែកុម្ភៈ ឆ្នាំ១៩៩៧ (ច្បាប់ស្តីពី ហិរញ្ញវត្ថុ ឆ្នាំ១៩៩៥) តែត្រូវបានធ្វើវិសោធនកម្មដ៏ធំនៅឆ្នាំ១៩៩៧ ។

• ច្បាប់ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៩៧ចេញដោយព្រះរាជក្រម និងអនុក្រឹត្យលេខ៨៨ អនុក្រ. បកថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

• អាករលើតម្លៃបន្ថែមត្រូវបានអនុម័តដោយព្រះរាជក្រមលេខ នស.រកម ០២៩៧ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ តែអនុម័តពិតប្រាកដគឺ ថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៩ ។

• អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា៤ និង ៦ថ្មីនៃច្បាប់ស្តីពីសារពើពន្ធដែលត្រូវបានធ្វើវិសោធនកម្មដោយមាត្រា១១ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ដែលប្រកាសប្រើដោយព្រះរាជក្រមលេខ នស.រកម. ១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ និងប្រកាសលេខ១៨២០ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពីការកំណត់វិធាន និងនីតិវិធីនៃការអនុវត្តបញ្ជីគណនេយ្យសាមញ្ញ សម្រាប់អ្នកជាប់ពន្ធតូច ។

សរុបរួមប្រវត្តិរបស់អង្គភាពពន្ធដារ

-1953: ត្រូវបានបង្កើតឡើងជានាយកដ្ឋានពន្ធដារ

-1975 ដល់ 1979: ពន្ធដារត្រូវលុបបំបាត់ចោលដោយរបបប៉ុលពត

-1980: នាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើងវិញ

-2008: នាយកដ្ឋានពន្ធដារបានដំឡើងទៅជាអគ្គនាយកដ្ឋានពន្ធដារដោយសាលាជាតិពន្ធដារ ។

### ៣.១.២ បេសកកម្ម ទស្សនវិស័យ និងភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ

**❈ បេសកកម្ម**

អគ្គនាយកដ្ឋានពន្ធដារ មានបេសកកម្មផ្តល់នូវសេវាកម្មដែលមានគុណភាព ពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព សាមញ្ញភាព និងសមធម៌ ដើម្បីជំរុញ អ្នកជាប់ពន្ធឱ្យបំពេញកាតព្វកិច្ចសារពើពន្ធដោយស្ម័គ្រចិត្តឈានទៅសម្រេចបាននូវការប្រមូលចំណូលពន្ធដារ ប្រកបដោយចីរភាពក្នុងគោលដៅលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា។

**❈ ទស្សនវិស័យ**

អគ្គនាយកដ្ឋានពន្ធដារ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានទស្សនវិស័យជាអង្គភាពសាធារណៈមួយដែលត្រូវបានទទួលស្គាល់ គោរព និងជឿទុកចិត្ត លើគុណភាព និងជំនាញក្នុងការប្រមូលចំណូលពន្ធដារ។

**❈ ភារកិច្ច**

អគ្គនាយកដ្ឋានពន្ធដារ មានភារកិច្ចដូចតទៅៈ

- ចូលរួមរៀបចំគោលនយោបាយសារពើពន្ធស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងបរិបទអន្តរជាតិ

-រៀបចំសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋានស្តីពីពន្ធដារ កំណត់បញ្ជីឯកសារ និងលិខិតយុត្តិការនានាសម្រាប់ការគ្រប់គ្រងប្រមូលពន្ធ

-ប្រមូលប្រាក់ពន្ធគ្រប់ប្រភេទបង់ចូលថវិកាជាតិ

-ចុះបញ្ជីអ្នកជាប់ពន្ធ

-ផ្តល់ការអប់រំដល់អ្នកជាប់ពន្ធអំពីកាតព្វកិច្ចសារពើពន្ធ

-ផ្តល់សេវា និងព័ត៌មានដល់អ្នកជាប់ពន្ធ ដើម្បីបង់ពន្ធឱ្យបានត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ

-កសាងកម្មវិធីសវនកម្ម និងធ្វើសវនកម្មលើអ្នកជាប់ពន្ធ

-កំណត់មូលដ្ឋានគិតពន្ធ ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់យឺតយ៉ាវ ចំពោះអ្នកជាប់ពន្ធស្របតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ

-ស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ

-អនុវត្តវិធានការតឹងទារ និងទោសទណ្ឌតាមច្បាប់ចំពោះអ្នកជាប់ពន្ធដែលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ

-ធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ

-រៀបចំ និងអនុវត្តកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិនានាទាក់ទិននឹងពន្ធដារ

-រៀបចំផែនការជ្រើសរើស បណ្តុះបណ្តាល និងកសាងសមត្ថភាពធនធានមនុស្សទាក់ទិននឹងពន្ធដារ

-ចូលរួមរៀបចំគម្រោងថវិកាជាតិ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ។

### ៣.១.៣ រចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារមានរចនាសម្ព័ន្ធដូចខាងក្រោមៈ

**ក- ថ្នាក់កណ្តាល**

-នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ

-នាយកដ្ឋានហិរញ្ញវត្ថុ និងបុគ្គលិក

-នាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ

-នាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ

-នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន

-នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ

-នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ

-នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូច និងមធ្យម

-នាយកដ្ឋានសវនកម្មសហគ្រាស

-សាលាជាតិពន្ធដារ ថ្នាក់ស្មើនាយកដ្ឋាន

-ទីចាត់ការពន្ធដាររាជធានីភ្នំពេញ ថ្នាក់ស្មើនាយកដ្ឋាន។

**ខ- ថ្នាក់មូលដ្ឋាន**

នៅខណ្ឌនានានៃរាជធានីភ្នំពេញ និងខេត្តនីមួយៗមានសាខាពន្ធដារខណ្ឌ និងសាខាពន្ធដារខេត្ត ដែលដឹកនាំដោយប្រធានមួយរូបមានឋានៈស្មើអនុប្រធាននាយកដ្ឋាននៅថ្នាក់កណ្តាល និងអនុប្រធានសាខាពន្ធដារមួយចំនួនមានឋានៈស្មើប្រធានការិយាល័យនៅថ្នាក់កណ្តាលជាជំនួយការ។

នៅស្រុក ក្រុង មានការិយាល័យពន្ធដារស្រុក ក្រុង មានថ្នាក់លើការិយាល័យនៃសាខាពន្ធដារខេត្ត-ខណ្ឌ និងដឹកនាំដោយប្រធានមួយរូបអមដោយអនុប្រធានមួយចំនួនជាជំនួយការ ។

## ៣.២ នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ

### ៣.២.១ ការចុះបញ្ជី និងការធ្វើបច្ចុប្បន្នភាពរបស់អ្នកជាប់ពន្ធ

ការចុះបញ្ជីពន្ធដារ គឺជាការចុះបញ្ជីអ្នកជាប់ពន្ធទាំងឡាយ ដែលធ្វើសកម្មភាពសេដ្ឋកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា។

១. បុគ្គលទាំងឡាយត្រូវចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងអំឡុងពេល១៥ (ដប់ប្រាំ)ថ្ងៃ ក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬសកម្មភាពផ្សេងទៀត រួមទាំងសកម្មភាពរបស់ស្ថាប័ន ឬអង្គការនានា ដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រា៥នៃច្បាប់នេះ។

២. បុគ្គលទាំងឡាយត្រូវជូនដំណឹងទៅរដ្ឋបាលសារពើពន្ធក្នុងរយៈពេល១៥ (ដប់ប្រាំ)ថ្ងៃ ក្រោយពីការផ្លាស់ប្តូរអាសយដ្ឋាន ទ្រង់ទ្រាយ នាមករណ៍ កម្មវត្ថុអាជីវកម្ម ការផ្ទេរ ការបញ្ឈប់អាជីវកម្ម សមាសភាពអ្នកគ្រប់គ្រង ឬអ្នកទទួលបន្ទុកកិច្ចការពន្ធដាររបស់សហគ្រាស។

រដ្ឋបាលសារពើពន្ធបានបង្កើតនីតិវិធីនៃការចុះបញ្ជីអ្នកជាប់ពន្ធ ដោយសារតែវាជាជំហានដំបូងនិងសំខាន់បំផុតក្នុងការគ្រប់គ្រងប្រព័ន្ធពន្ធដារឱ្យមានប្រសិទ្ធភាព។ ការចុះបញ្ជីពន្ធដារនេះមានគោលបំណងសំខាន់ៗដូចខាងក្រោម៖

១. ដើម្បីឱ្យរដ្ឋបាលសារពើពន្ធអាចគ្រប់គ្រង និងតាមដានប្រាក់ចំណូលរបស់អ្នកជាប់ពន្ធបានយ៉ាងមានប្រសិទ្ធភាព៖

• អ្នកជាប់ពន្ធដែលបានចុះបញ្ជីអាចទទួលបានសិទ្ធិប្រើប្រាស់សេវាកម្មរដ្ឋ ដូចជាៈ ការដាក់ពាក្យសុំឯកសារ, ការចូលរួមក្នុងសំណើរ ឬការទិញសាធារណៈ។

• វាជាប្រភពសំខាន់មួយនៃការធ្វើឱ្យប្រព័ន្ធរដ្ឋបាលសារពើពន្ធមានភាពស្របច្បាប់ តម្លាភាព និងគួរឱ្យទុកចិត្តពីសាធារណៈជន។

២. បង្កើតភាពស្មើភាពគ្នាក្នុងការបង់ពន្ធ

• ការចុះបញ្ជីធានាថាបុគ្គលគ្រប់រូបមានកាតព្វកិច្ចក្នុងការបង់ពន្ធដូចគ្នា បើសិនជាមានប្រាក់ចំណូល

• ជួយលុបបំបាត់អំពើរើសអើង និងការទទួលអត្ថប្រយោជន៍ដោយមិនសមស្រប

• អ្នកដែលចុះបញ្ជី គឺត្រូវបានចាត់ទុកជាអ្នកស្របច្បាប់ និងមានសិទ្ធិស្មើគ្នាក្នុងការទទួលសេវាកម្មពីរដ្ឋ។

៣. ជាជំហានដំបូងក្នុងការទប់ស្កាត់បទល្មើសពន្ធដារ

• ការមិនចុះបញ្ជី គឺជារបៀបមួយនៃការលាក់ប្រាក់ចំណូល និងការគេចវេះកាតព្វកិច្ចក្នុងការបង់ពន្ធ

• ការចុះបញ្ជីធ្វើឱ្យរដ្ឋបាលសារពើពន្ធអាចរកឃើញអ្នកគេចពន្ធ ឬមិនបានបង់ពន្ធឱ្យបានត្រឹមត្រូវ

• ជួយបង្កើនប្រសិទ្ធិភាពនៃការគ្រប់គ្រងព័ត៌មានរបស់អ្នកជាប់ពន្ធ និងធ្វើឱ្យបទល្មើសពន្ធកើតមានកាន់តែតិច។

៤. ដើម្បីបង្កើតប្រព័ន្ធពន្ធដារដែលគួរជាទីជឿទុកចិត្ត និងមានគុណភាព

• អ្នកជាប់ពន្ធដែលបានចុះបញ្ជីអាចទទួលបានសិទ្ធិប្រើប្រាស់សេវាកម្មរដ្ឋ ដូចជាៈ ការដាក់ពាក្យសុំឯកសារ, ការចូលរួមក្នុងសំណើរ ឬការទិញសាធារណៈ។

• វាជាប្រភពសំខាន់មួយនៃការធ្វើឱ្យប្រព័ន្ធរដ្ឋបាលសារពើពន្ធមានភាពស្របច្បាប់ តម្លាភាព និងគួរឱ្យទុកចិត្តពីសាធារណជន។

**៣.២.២ ការបង់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិក**

ការបង់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិក ជាវិធានការទប់ស្កាត់បទល្មើសពន្ធដារមួយមានន័យថា ការប្រើប្រាស់ច្ចេកវិទ្យាឌីជីថលដើម្បីធានាថា ប្រព័ន្ធបង់ពន្ធមានភាពថ្លៃថ្នូរ សុចរិត និងមានប្រសិទ្ធភាព។ វាជួយកាត់បន្ថយបទល្មើសពន្ធ ដូចជា ការបំបាំងចំណូល ឬការបង្កើតឯកសារក្លែងបន្លំ។

អគ្គនាយកដ្ឋានពន្ធដារ បានដាក់ឱ្យប្រើប្រាស់នូវការប្រកាសពន្ធតាមប្រព័ន្ធអនឡាញ E-Filing សម្រាប់អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំទាំងអស់ រួមទាំងអង្គការសង្គមស៊ីវិលផងដែរ ។ ប្រព័ន្ធ E-Filing នេះ នឹងអនុញ្ញាតឱ្យអង្គការសង្គមស៊ីវិល ដាក់ឯកសារ ឬប្រកាសពន្ធលើប្រាក់បៀវត្ស (ToS) ពន្ធកាត់ទុក (WHT) អាករលើតម្លៃបន្ថែម ប្រតិបត្តិការសំខាន់ៗ និងពន្ធ ផ្សេងទៀតតាមរយៈ ការប្រកាសពន្ធតាមប្រព័ន្ធអនឡាញប្រចាំខែរបស់ GDT ។

❋ សារៈសំខាន់នៃការបង់ពន្ធតាមប្រព័ន្ធ E-Filing អាចកាត់បន្ថយបទល្មើសពន្ធដារមួយចំនួនដូចជាៈ

• បង្កើនប្រសិទ្ធិភាព និងសុចរិតភាព តាមរយៈការបង់ពន្ធតាមប្រព័ន្ធ E-Filing ដោយអនុញ្ញាតឱ្យអ្នកជាប់ពន្ធបញ្ចូលព័ត៌មានផ្ទាល់ខ្លួនដោយគ្មានការទាក់ទងផ្ទាល់ជាមួយមន្ត្រីពន្ធដារ។ វាជួយកាត់បន្ថយឱកាសនៃអំពើពុករលួយ និងធានាបាននូវភាពស្មើភាពក្នុងការប្រើប្រាស់ច្បាប់។

• ការត្រួតពិនិត្យប្រសិទ្ធភាពតាមប្រព័ន្ធ E-Filing រួមបញ្ចូលនូវប្រព័ន្ធត្រួតពិនិត្យស្វ័យប្រវត្តិដែលអាចស្វែងរកការបញ្ចូលព័ត៌មានក្លែងក្លាយ ឬការបន្លំពន្ធបានយ៉ាងមានប្រសិទ្ធភាព។ វាជួយសម្រួលការអនុវត្តច្បាប់ឱ្យបានឆាប់រហ័ស និងត្រឹមត្រូវ។

• ជម្រុញឱ្យអ្នកជាប់ពន្ធបំពេញកាតព្វកិច្ចរបស់ខ្លួនដោយស្ម័គ្រចិត្តតាមរយៈប្រព័ន្ធ E-Filing ដែលមានលក្ខណៈងាយស្រួលប្រើប្រាស់ តាមកុំព្យូទ័រ ឬស្មាតហ្វូន។ ភាពងាយស្រួលនេះធ្វើឱ្យអាជីវករនិងសហគ្រាសមានចិត្តស្ម័គ្រចិត្តក្នុងការបង់ពន្ធត្រឹមត្រូវ និងទាន់ពេលវេលា។

• កាត់បន្ថយការបាត់បង់ប្រាក់ពន្ធ ដោយសារតែប្រព័ន្ធ E-Filing អាចកត់ត្រា និងរក្សាទិន្នន័យពន្ធបានយ៉ាងច្បាស់លាស់ វាបង្កើនភាពច្បាស់លាស់ក្នុងការបង់ពន្ធ និងជួយឱ្យរដ្ឋបាលសារពើពន្ធអាចប្រមូលប្រាក់ពន្ធបានគ្រប់គ្រាន់ ដោយមិនបាត់បង់ទៅដោយហេតុផលខុសច្បាប់។

ប្រព័ន្ធ E-Filing ជាឧបករណ៍សំខាន់មួយសម្រាប់ការពង្រឹងប្រព័ន្ធពន្ធដារនៅកម្ពុជា មិនត្រឹមតែបង្កើនប្រសិទ្ធភាពនៃការបង់ពន្ធទេ ប៉ុន្តែអាចជាជំហានដ៏សំខាន់ក្នុងការកាត់បន្ថយ និងទប់ស្កាត់បទល្មើសពន្ធដារ ដោយផ្អែកលើសុចរិតភាព តម្លាភាព និងបច្ចេកវិទ្យាទំនើប។

**៣.២.៣ វិសាលភាព បែបបទ និងនីតិវិធីនៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ**

**១. វិសាលភាពនៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ**

ក្នុងករណីដែលរកឃើញ ដាយថាហេតុនូវភ័ស្តុតាងដែលបញ្ជាក់ថាពិតជាមានអំពើគេចវេះពន្ធ ដែលកើតមានឡើងដោយចេតនារៀបចំរបស់អ្នកជាប់ពន្ធ ឬបទល្មើសជាក់ស្តែងដែលអ្នកជាប់ពន្ធ បាននិងកំពុងប្រព្រឹត្ត រដ្ឋបាលសារពើពន្ធអាចចុះធ្វើការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិ ស្តីពីពន្ធដារទៅលើអ្នកជាប់ពន្ធ។

អ្នកជាប់ពន្ធដែលទទួលបានវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទមាស មិនត្រូវទទួល រងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារទេ ក្នុងអំឡុងពេលវិញ្ញាបនបត្រនោះ កំពុងមានសុពលភាព។ ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីរកឃើញថាអ្នកជាប់ពន្ធបានប្រព្រឹត្តបទល្មើស ព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ រដ្ឋបាលសារពើពន្ធអាចចុះស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ។

**២. បែបបទ និងនីតិវិធីនៃការអនុវត្តការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ**

· មុនពេលបើកការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ

តាមរយៈនាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ អគ្គនាយកដ្ឋានពន្ធដារធ្វើការប្រមូលព័ត៌មានពីបណ្តាប្រភពពាក់ព័ន្ធនានា ដើម្បីពិនិត្យផ្ទៀងផ្ទាត់ និងវិភាគរកកត្តាហានិភ័យទាំងឡាយដែល ជាផ្នែកមួយឬទាំងស្រុងនៃការបំពាន ឬការគំរាមកំហែងណាមួយចំពោះប្រព័ន្ធពន្ធដារ។ តាមរយៈលទ្ធផល នៃការវិភាគទាំងនេះ អគ្គនាយកដ្ឋានពន្ធដារអាចឈានទៅដល់ការកំណត់បាននូវតម្រុយ ឬនិន្នាការ នៃការគេចវេះពន្ធ ឬ

វិស័យ និងប្រភេទអ្នកជាប់ពន្ធដែលចាត់ទុកថាមានហានិភ័យខ្ពស់ ឬមានជាប់ទាក់ទិនទៅនឹងការគេចវេះពន្ធ។ នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ ធ្វើការកំណត់ និងជ្រើសរើស សំណុំរឿង ឬករណីដែលមានសូចនាករ ឬតម្រុយច្បាស់លាស់នៃការគេចវេះពន្ធ ឬភ័ស្តុតាងបញ្ជាក់ ពីបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារប្រាកដមែន បន្ទាប់មកទើបធ្វើការស្នើសុំគោលការណ៍ អនុញ្ញាតដើម្បីបើកការស៊ើបអង្កេតតាមច្បាប់ជាធរមាន។

នៅពេលនាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ ទទួលបានគោលការណ៍អនុញ្ញាតឱ្យបើកការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារលើអ្នកជាប់ពន្ធណាមួយ ប្រសិនបើ អ្នកជាប់ពន្ធនោះកំពុងត្រូវបានធ្វើសវនកម្ម អង្គភាពដែលកំពុងធ្វើសវនកម្មត្រូវបញ្ឈប់ការធ្វើសវនកម្ម ហើយត្រូវបង្វែរករណីអ្នកជាប់ពន្ធទៅនាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារធ្វើការស៊ើបអង្កេតទៅតាម បែបបទ និងនីតិវិធី ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។ ប្រសិនបើលទ្ធផលនៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ លើអ្នកជាប់ពន្ធ ដែលត្រូវបានបញ្ជូនដោយអង្គភាពធ្វើសវនកម្ម មិនឈានដល់ការប្តឹងទៅតុលាការទេ នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ ត្រូវបង្វែរករណីនោះ ទៅអង្គភាពធ្វើសវនកម្មវិញដើម្បីបន្ត នីតិវិធីសវនកម្ម។ ក៏ដូចគ្នាដែរ នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ ត្រូវបង្វែរគ្រប់ករណីអ្នកជាប់ពន្ធ ដែលត្រូវបានទទួលរងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដែលមិនឈានដល់ការប្តឹងទៅតុលាការ ទៅអង្គភាពធ្វើសវនកម្មដើម្បីធ្វើសវនកម្ម តាមបែបបទ និងនីតិវិធីជាធម្មតា។

បែបបទ និងនីតិវិធីនៃការកសាងសំណុំរឿងស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពី ពន្ធដារ ត្រូវធ្វើឡើងតាមជំហានដូចខាងក្រោម៖

ក. ប្រមូលព័ត៌មានពីប្រភពទាំងឡាយដែលទាក់ទិន នឹងករណីសង្ស័យ ឬភ័ស្តុតាងពាក់ព័ន្ធ នឹងបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ បន្ថែមពីលើព័ត៌មានដែលមានស្រាប់ ដែលក្នុងនោះរួមបញ្ចូលទាំងការប្រមូលព័ត៌មានពីប្រព័ន្ធគ្រប់គ្រងទិន្នន័យអ្នកជាប់ពន្ធ របស់អគ្គនាយកដ្ឋានពន្ធដារ។

ខ. ពិនិត្យ វិភាគ ផ្ទៀងផ្ទាត់ និងវាយតម្លៃគ្រប់ជ្រុងជ្រោយ ចំពោះព័ត៌មានដែលប្រមូលបាន ពីប្រភពពាក់ព័ន្ធទាំងឡាយ ដូចមានលើកឡើងក្នុងចំណុច ក ខាងលើ ដើម្បីកំណត់ សូចនាករនៃការក្លែងបន្លំ ឬភ័ស្តុតាងបញ្ជាក់ឱ្យបានច្បាស់ថាជាបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ។

គ. បន្ទាប់ពីពិនិត្យឃើញថា ពិតជាមានសូចនាករ ឬតម្រុយច្បាស់លាស់នៃការក្លែងបន្លំ ឬភ័ស្តុតាងបញ្ជាក់ពីបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារប្រាកដមែន នោះអង្គភាពដែលមានមុខងារ និងភារកិច្ចធ្វើការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ លើបទប្បញ្ញត្តិស្តីពីពន្ធដារ នឹងរៀបចំសំណុំឯកសារ ដើម្បីស្នើសុំកសាងសំណុំរឿងស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ។

- អំឡុងពេលធ្វើការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ

យោងតាមមាត្រា២៣០ នៃច្បាប់ស្តីពីសារពើពន្ធ នៅពេលចូលទៅក្នុងគ្រឹះស្ថានអាជីវកម្ម ឬទីកន្លែងដែលត្រូវបានចាត់ទុកថាជាគ្រឹះស្ថានអាជីវកម្ម មន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិ ស្តីពីពន្ធដារមានអំណាចក្នុងការស៊ើបអង្កេតដូចខាងក្រោម៖

១- ចូលទៅក្នុងគ្រឹះស្ថានអាជីវកម្ម ឬទីកន្លែងដែលត្រូវចាត់ទុកថាជាគ្រឹះស្ថានអាជីវកម្មដើម្បី ពិនិត្យបញ្ជីគណនេយ្យ លិខិតប្រកាសសារពើពន្ធគ្រប់ប្រភេទ និងឯកសារពាក់ព័ន្ធផ្សេងៗ ដើម្បីកំណត់ពន្ធ។ ការចូលគ្រឹះស្ថានអាជីវកម្មដូចមានចែងក្នុងកថាខណ្ឌនេះ ត្រូវធ្វើឡើងក្នុងម៉ោងអាជីវកម្ម ឬនៅគ្រប់ពេលវេលាដោយអនុវត្តតាមដីការបស់ស្ថាប័នអយ្យការ ឬ

២- នៅពេលដែលបានចូលដោយស្របច្បាប់ទៅក្នុងគ្រឹះស្ថានអាជីវកម្ម ឬទីកន្លែងដែលត្រូវចាត់ទុកថាជាគ្រឹះស្ថានអាជីវកម្មដូចដែលមានចែងក្នុងកថាខណ្ឌទី១នៃមាត្រា២៣០ នៃច្បាប់ស្តីពីសារពើពន្ធ មន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារមានសិទ្ធិ៖

ក. ធ្វើសម្រង់ ឬចម្លងឯកសារនានា រួមទាំងឯកសារអេឡិចត្រូនិកដែលស្ថិតនៅក្នុងកន្លែងនោះ។

ខ. ចាប់យកឯកសារនានា ឬវត្ថុតាងដទៃទៀតដែលអាចក្លាយជាព័ត៌មាន ឬភ័ស្តុតាង សម្រាប់កំណត់ប្រាក់ពន្ធដែលត្រូវបង់របស់បុគ្គលណាម្នាក់ ដោយត្រូវធ្វើកំណត់ហេតុ ស្តីពីការចាប់យក។

គ. ដាក់ឧបករណ៍សម្រាប់ត្រួតពិនិត្យផ្សេងៗ ឬបោះត្រាបិទសម្គាល់ ឃាត់ទុកទំនិញ ប្រសិនបើមានជាប់ទាក់ទិនដល់ការអនុវត្តពន្ធណាមួយ។

ឃ. ធ្វើសារពើភណ្ឌទ្រព្យសកម្ម វត្ថុធាតុដើម ផលិតផលកំពុងផលិត ផលិតផលសម្រេច និងស្តុក/សន្និធិដទៃទៀត។

ង. ចាប់យក ឃាត់ទុក ឬឃុំគ្រងទ្រព្យសម្បត្តិអ្នកជាប់ពន្ធដើម្បីធានាបំណុលពន្ធ។

ច. ឃាត់ខ្លួនអ្នកជាប់ពន្ធ ដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដោយអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

៣- ក្នុងគ្រប់ករណីទាំងអស់ នៅពេលមានការរកឃើញបទល្មើសព្រហ្មទណ្ឌលើ បទប្បញ្ញត្តិស្តីពី ពន្ធដារ នៅក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតរបស់មន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើ បទប្បញ្ញត្តិស្តីពីពន្ធដារ ប្រតិបត្តិការរបស់មន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើ បទប្បញ្ញត្តិស្តីពីពន្ធដារទាក់ទិននឹងការប្រមូលភ័ស្តុតាង ការធ្វើកំណត់ហេតុ និងការអនុវត្តរាល់កិច្ចនីតិវិធីព្រហ្មទណ្ឌចាំបាច់ដទៃទៀត ដោយរួមទាំងការឃាត់ខ្លួនជនសង្ស័យផង ត្រូវធ្វើឡើងដោយមន្ត្រីពន្ធដារ ដែលមាននីតិសម្បទាជាមន្ត្រី ឬភ្នាក់ងារនគរបាលយុត្តិធម៌ ហើយត្រូវអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

៤- អាចតម្រូវឱ្យស្ថាប័នធនាគារដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ផ្តល់ព័ត៌មានអំពី គណនីរបស់អ្នកជាប់ពន្ធ ឬបុគ្គលពាក់ព័ន្ធនៅធនាគា ឬឃាត់ទុកគណនីរបស់អ្នកជាប់ពន្ធ ឬបុគ្គលពាក់ព័ន្ធនោះ ក្នុងករណីមានភ័ស្តុតាងបញ្ជាក់ថាបានប្រព្រឹត្តអំពើគេចវេះពន្ធ។

- ក្រោយពេលស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ

យោងតាមមាត្រា១៩៣ និងមាត្រា១៩៤ នៃច្បាប់ស្តីពីសារពើពន្ធ បន្ទាប់ពីបានកំណត់អត្តិភាព បទល្មើស បុគ្គលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ឬករណីគេចវេះពន្ធ និង/ឬអំពើរាំងស្ទះកម្រិតធ្ងន់ធ្ងរដោយចេតនារបស់អ្នកជាប់ពន្ធរួចហើយ មន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើ បទប្បញ្ញត្តិស្តីពីពន្ធដារ នឹងធ្វើការអញ្ជើញអ្នកជាប់ពន្ធនោះមកជួប ដើម្បីពន្យល់បកស្រាយអំពីលទ្ធផលនៃ ការស៊ើប

អង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដែលជាអាទិ៍មាន មូលដ្ឋាន និងភ័ស្តុតាងដែលគាំទ្រដល់ការកំណត់អត្ថិភាពបទល្មើស បុគ្គលប្រព្រឹត្តបទល្មើស មូលដ្ឋាននៃការកំណត់ពន្ធ ការកំណត់ពន្ធឡើងវិញ និងការកសាងសំណុំរឿងទៅតុលាការជាដើម។

ប្រសិនបើការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារមិនឈានដល់ការ កសាងសំណុំរឿងទៅតុលាការទេនោះនាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារនៃអគ្គនាយកដ្ឋានពន្ធដារ ត្រូវបង្វែរករណីនោះទៅអង្គភាពពាក់ព័ន្ធដើម្បីបន្តនីតិវិធីសវនកម្មវិញ។

អនុលោមតាមមាត្រា២២៧ នៃច្បាប់ស្តីពីសារពើពន្ធ បណ្តឹងអាជ្ញាចំពោះបទល្មើសព្រហ្មទណ្ឌ លើបទប្បញ្ញត្តិស្តីពីពន្ធដារ ដែលអគ្គនាយកដ្ឋានពន្ធដារបានប្ដឹងទៅតុលាការ អាចត្រូវបានរំលត់ តាមរយៈការស្នើសុំសម្របសម្រួលពីសំណាក់អ្នកជាប់ពន្ធ ដោយធ្វើការបង់ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់ ឱ្យគ្រប់ចំនួនតាមការកំណត់។ ក្នុងករណីយល់ព្រម អគ្គនាយកដ្ឋានពន្ធដារត្រូវធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីពិនិត្យ និងសម្រេច និងត្រូវធ្វើកំណត់ហេតុ ស្តីពីការសម្របសម្រួលជូន ស្ថាប័នអយ្យការ ឬស្ថាប័នតុលាការ។

❋ **ទណ្ឌកម្មព្រហ្មទណ្ឌតាមបទប្បញ្ញត្តិស្តីពីសារពើពន្ធ**

ដោយមិនទាន់គិតដល់ទណ្ឌកម្មរដ្ឋបាល និងទណ្ឌកម្មផ្សេងទៀត៖

· ទណ្ឌកម្មព្រហ្មទណ្ឌចំពោះរូបវន្តបុគ្គល ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌលើ បទប្បញ្ញត្តិស្តីពីពន្ធដារ រួមមាន៖

- ដាក់ពន្ធនាគារពី ១ (មួយ)ខែ ទៅ ៥ (ប្រាំ)ឆ្នាំ
- និងពិន័យជាប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀល ដល់ ២០០ ០០០ ០០០ (ពីររយលាន) រៀល ទៅតាមបទល្មើសនីមួយៗ ដូចមានចែងក្នុងមាត្រា២៤២ មាត្រា២៤៣ មាត្រា ២៤៥ មាត្រា២៤៦ មាត្រា២៤៧ និងមាត្រា២៥០ នៃច្បាប់ស្តីពីសារពើពន្ធ។

## ៣.៣ គោលការណ៍ដើម្បីកំណត់បទល្មើសអ្នកជាប់ពន្ធ

### ៣.៣.១ បទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ

បទល្មើសដែលចាប់ទុកថាជាបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ គឺសំដៅដល់បុគ្គលទាំងឡាយណា ដែលបានប្រព្រឹត្តទៅលើបទល្មើសដូចជា ការគេចវេះពន្ធ និងអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ។ បទល្មើសលើការគេចវេះពន្ធ គឺចង់សំដៅទៅដល់លក្ខណៈពិសេសរបស់បុគ្គលទាំងឡាយណាដែលបានប្រព្រឹត្តដោយចេតនាដោយមិនចង់បង់ពន្ធ មួយវិញទៀតចំពោះបុគ្គលដែលបានដឹងមុនហើយថាមានកាតព្វកិច្ចត្រូវតែបង់ពន្ធ ប៉ុន្តែបុគ្គលនោះព្យាយាមស្វែងរកវិធីគេចវេះថែមទាំងបានប្រព្រឹត្តវាជាច្រើនដងលើការរៀបចំទុកនូវផែនការនោះដោយមានគោលបំណង ចង់កាត់បន្ថយប្រាក់ពន្ធ ឬចង់បំបាត់ប្រាក់ពន្ធ។ មិនតែប៉ុណ្ណោះ មានបុគ្គលមួយចំនួនទៀតមិនចង់បង់ពន្ធនោះ១០០%តែម្តង ដែលគេចាប់ទុកថាជាបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិ។

ចំពោះអំពើរាំងស្ទះការអនុវត្តបទបប្បញ្ញត្តិស្តីពីពន្ធដារសំដៅដល់បុគ្គលទាំងឡាយណាដែលមិនបានរក្សាបញ្ជីកាគណនេយ្យ និងឯកសារផ្សេងៗ ឬមិនបានចេញវិក្កយបត្រលើកិច្ចការជំនាញ មិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធធ្វើការពិនិត្យបញ្ជីកាគណនេយ្យ ឬឯកសារផ្សេងៗ ដែលបុគ្គលមិនបានចុះបញ្ជីនៅរដ្ឋបាល

សារពើពន្ធ និងមិនបានជូនដំណឹងទៅរដ្ឋបាលសាពើពន្ធអំពីការផ្លាស់ប្ដូរក្នុងការចុះបញ្ជីជាដើម ដែលទាំងអស់នេះហៅថា អំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ។

**៣.៣.២ គោលការណ៍កំណត់បទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ**

អនុលោមតាមបទប្បញ្ញត្តិដូចមានចែងក្នុងផ្នែកទី៥ នៃជំពូកទី១៨ នៃច្បាប់ស្តីពីសារពើពន្ធ ចំពោះអ្នកជាប់ពន្ធដែលប្រព្រឹត្តសកម្មភាពទាំងបីខាងក្រោមនេះត្រូវចាត់ទុកជាបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ រួមមាន៖

១. "ការគេចវេះពន្ធ" (មាត្រា២២៦នៃច្បាប់ស្តីពីសារពើពន្ធ) គឺជាអំពើណាមួយ ដែលបានប្រព្រឹត្តឡើងដោយចេតនា និងរៀបចំទុកជាមុនដែលនាំឱ្យបាត់ប្រាក់ពន្ធដែលបទប្បញ្ញត្តិស្តីពីពន្ធដារតម្រូវឱ្យបង់។ ត្រូវបានចាត់ទុកថាជាការគេចវេះពន្ធផងដែរចំពោះករណីណាមួយដូចខាងក្រោម៖

- ការធ្វេសប្រហែសធ្ងន់ធ្ងរដូចមានចែងក្នុងមាត្រា២២៤ នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានប្រព្រឹត្តឡើងពីរលើកដាច់ពីគ្នាក្នុងរយៈពេល៣(បី)ឆ្នាំ នៃឆ្នាំប្រតិទិន។
- ការធ្វេសប្រហែសធ្ងន់ធ្ងរដូចមានចែងក្នុងមាត្រា២២៤ នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានប្រព្រឹត្តឡើងបីលើក ឬច្រើនជាងនេះដាច់ពីគ្នាក្នុងរយៈពេល១០ (ដប់)ឆ្នាំ នៃឆ្នាំប្រតិទិន។

២. "អំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ" ត្រូវបានចាត់ទុកជាអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ចំពោះអំពើដែលប្រព្រឹត្តផ្ទុយពីការកំណត់របស់ច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតដូចខាងក្រោម៖

- ការមិនបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ស្របតាមការកំណត់របស់ច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត។
- ការមិនបានជូនដំណឹងទៅរដ្ឋបាលសារពើពន្ធអំពីការផ្លាស់ប្តូរព័ត៌មាននៃការចុះបញ្ជី។
- ការមិនបានដាក់លិខិតប្រកាសសារពើពន្ធ។
- ការមិនបានប្រើប្រាស់ប្រព័ន្ធកត់ត្រាដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ។
- ការមិនបានចេញវិក្កយបត្រ។
- ការមិនផ្តល់ព័ត៌មាន ឬមិនបញ្ជូនរបាយការណ៍តាមការស្នើសុំ។
- ការមិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធធ្វើការពិនិត្យបញ្ជីកាគណនេយ្យ ឬឯកសារផ្សេងៗ។
- ការមិនបានរក្សាបញ្ជីកាគណនេយ្យ និងឯកសារផ្សេងទៀត។
- ការព្យាយាមរារាំងការកំណត់ និងការប្រមូលពន្ធ។
- ការកសាង ឬផ្តល់នូវកំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានក្លែងបន្លំ។
- ការលាក់ទុក ឬបំផ្លាញចោលដោយចេតនានូវបញ្ជីកាគណនេយ្យ កំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានផ្សេងៗ។
- ការចេញវិក្កយបត្រក្លែងបន្លំ។
- ការមិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធចូលគ្រឹះស្ថានអាជីវកម្មដើម្បីកំណត់និងប្រមូលពន្ធ។

៣. សកម្មភាពមួយចំនួនដែលចែងក្នុងមាត្រា២៤៥ មាត្រា២៤៦ មាត្រា២៤៧ មាត្រា២៤៩ និងមាត្រា២៥០ នៃច្បាប់ស្តីពីសារពើពន្ធ ក្នុងនោះមាន៖

- ប្រកបវិជ្ជាជីវៈជាភ្នាក់ងារសេវាកម្មពន្ធដារដោយគ្មានអាជ្ញាបណ្ណ
- ខកខានមិនបានបង់ប្រាក់ពន្ធដែលបានប្រមូលរួច
- ប្រមូលប្រាក់ពន្ធដែលមិនមានសិទ្ធិប្រមូល។

**៣.៣.៣ ទណ្ឌកម្មព្រហ្មទណ្ឌតាមបទប្បញ្ញត្តិស្តីពីពន្ធដារ**

បទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ត្រូវទទួលរងទណ្ឌកម្មព្រហ្មទណ្ឌតាមបទប្បញ្ញត្តិ ស្តីពីពន្ធដារដូចខាងក្រោមៈ

**មាត្រា២៤២** បទល្មើសគេចវេះពន្ធ

ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌផ្សេងទៀត អភិបាល បណ្ណាធិការ កម្មសិទ្ធិករ របស់សហគ្រាសណាមួយ ឬបុគ្គលទទួលខុសត្រូវឱ្យសហគ្រាសណាមួយដែលបានប្រព្រឹត្តអំពើគេចវេះពន្ធដូចមាន ចែងក្នុងមាត្រា២២៦នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០ ០០០ (មួយរយលាន) រៀល ទៅ២០០ ០០០ ០០០ (ពីររយលាន) រៀល។

**មាត្រា២៤៣** បទល្មើសរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ

ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី៥០ ០០០ ០០០ (ហាសិបលាន) រៀល ទៅ១០០ ០០០ ០០០ (មួយរយលាន) រៀល។

**មាត្រា២៤៥** ការប្រកបវិជ្ជាជីវៈជាភ្នាក់ងារសេវាកម្មពន្ធដារដោយគ្មានអាជ្ញាបណ្ណ

ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌផ្សេងទៀត បុគ្គលដែលប្រកបវិជ្ជាជីវៈជាភ្នាក់ងារសេវាកម្មពន្ធដារដោយគ្មានអាជ្ញាបណ្ណ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន) រៀល ទៅ២០ ០០០ ០០០ (ម្ភៃលាន) រៀល។

**មាត្រា២៤៦** ការខកខានមិនបានបង់ប្រាក់ពន្ធដែលបានប្រមូលរួច

ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌផ្សេងទៀត បុគ្គលដែលខកខានមិនបានបង់ប្រាក់ពន្ធ ដែលបានប្រមូលរួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី ៥០ ០០០ ០០០(ហាសិបលាន) រៀល ទៅ១០០ ០០០ ០០០(មួយរយលាន) រៀល។

**មាត្រា២៤៧** ការប្រមូលប្រាក់ពន្ធដែលមិនមានសិទ្ធិប្រមូល

ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌផ្សេងទៀត បុគ្គលដែលធ្វើការប្រមូលប្រាក់ពន្ធ ដោយមិនទទួលបានសិទ្ធិពីរដ្ឋ ឬការអនុញ្ញាតស្របតាមការកំណត់របស់ច្បាប់នេះ ឬលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី៥០ ០០០ ០០០ (ហាសិបលាន) រៀល ទៅ១០០ ០០០ ០០០ (មួយរយលាន)

**មាត្រា២៤៩** ការទទួលខុសត្រូវរបស់នីតិបុគ្គល

- នីតិបុគ្គលអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា២៤២ មាត្រា២៤៣ មាត្រា២៤៥ មាត្រា២៤៦ មាត្រា២៤៧ និងមាត្រា២៥០នៃច្បាប់នេះ។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

ជាការពិតណាស់ ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយលើការអនុវត្តការងារ ឬច្បាប់ដែលបានកំណត់តែងតែមាន។ ការវាយតម្លៃវាមានសារៈសំខាន់ណាស់ដើម្បីឱ្យយើងដឹងពីចំណុចខ្លាំង និងចំណុចខ្សោយសម្រាប់យកមកកែតម្រូវដើម្បីឱ្យមានភាពច្បាស់លាស់បន្ថែមទៀតក្នុងការគ្រប់គ្រង និងការអនុវត្តជាក់ស្តែង។ ក្នុងនោះដែរ បន្ទាប់ពីក្រុមនាងខ្ញុំ បានធ្វើការស្រាវជ្រាវអស់រយៈពេលកន្លងមកចំពោះប្រធានបទស្តីពី «**នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ**» រួចមក ក្រុមនាងខ្ញុំបានរកឃើញនូវចំណុចខ្លាំង និងចំណុចខ្សោយមួយចំនួន ដូចតទៅ៖

## ៤.១ ការវិភាគលើចំណុចខ្លាំង

១. គោលការណ៍កំណត់បទល្មើសអ្នកជាប់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារមានការចែងជាច្បាប់ និងមាត្រាច្បាស់លាស់ អំពីការគេចវេះពន្ធ អំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ និងសកម្មភាពមួយចំនួនដែលចែងក្នុងមាត្រា២៤៥ មាត្រា២៤៦ មាត្រា២៤៧ មាត្រា២៤៩ និងមាត្រា២៥០ ការបែងចែកនេះជួយឱ្យមានភាពច្បាស់លាស់ក្នុងការដាក់ពិន័យ និងងាយស្រួលដោះស្រាយទៅតាមករណីជាក់លាក់។

២. ការជម្រុញឱ្យអ្នកជាប់ពន្ធទាំងអស់ទៅចុះបញ្ជីពន្ធដារ ព្រោះការចុះបញ្ជីធ្វើឱ្យរដ្ឋបាលសារពើពន្ធអាចរកឃើញអ្នកគេចវេះពន្ធ ឬមិនបានបង់ពន្ធឱ្យបានត្រឹមត្រូវ ព្រមទាំងជួយបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងព័ត៌មានរបស់អ្នកជាប់ពន្ធ និងធ្វើឱ្យបទល្មើសពន្ធកើតមានកាន់តែតិច។

៣. រដ្ឋបាលសារពើពន្ធបានប្រើប្រាស់ការបង់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិកតាមរយៈ ប្រព័ន្ធអនឡាញ E-Filing ដែលអាចកាត់បន្ថយការបាត់បង់ប្រាក់ពន្ធ ដោយសារតែប្រព័ន្ធ E-Filing អាចកត់ត្រា និងរក្សាទិន្នន័យពន្ធបានយ៉ាងច្បាស់លាស់ វាបង្កើនភាពច្បាស់លាស់ក្នុងការបង់ពន្ធ និងជួយឱ្យរដ្ឋបាលសារពើពន្ធអាចប្រមូលប្រាក់ពន្ធបានគ្រប់គ្រាន់ ដោយមិនបាត់បង់ទៅដោយហេតុផលខុសច្បាប់។

៤. រដ្ឋបាលសារពើពន្ធមានបែបបទ និងនីតិវិធីក្នុងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ តាមលំដាប់លំដោយ មុនពេលបើកការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ អំឡុងពេលធ្វើការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ និងក្រោយពេលស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ការធ្វើតាមដំណាក់កាលបែបនេះធានាបាននូវភាពច្បាស់លាស់ និងស្របតាមច្បាប់។

## ៤.២ ការវិភាគលើចំណុចខ្សោយ

ទន្ទឹមនឹងចំណុចខ្លាំងដែលលើកឡើងមកខាងលើ តាមរយៈការស្រាវជ្រាវរបស់ក្រុមនាងខ្ញុំក៏មើលឃើញអំពីកង្វះខាតមួយចំនួនដែលតម្រូវឱ្យមានការយកចិត្តទុកដាក់បន្ថែមដើម្បីឱ្យការប្រមូលពន្ធកាន់តែប្រសើរឡើងដូចជា៖

១. រដ្ឋបាលសារពើពន្ធ មិនបានដាក់ចេញនូវលទ្ធផលតឹងរឹងទៅលើអ្នកប្រកបអាជីវកម្ម ដែលមិនចង់ទៅចុះបញ្ជីពន្ធដារ ដែលជាបញ្ហាសំខាន់មួយដែលធ្វើឱ្យការប្រមូលពន្ធមិនបានពេញលេញ។

២. ការបង់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិក បង្ករការលំបាកដល់អ្នកប្រើប្រាស់ ដោយសារតែអ្នកប្រើប្រាស់មានកម្រិតសមត្ថភាពបច្ចេកទេសមិនស្មើគ្នា( ពិសេសអ្នកនៅជនបទ ) មិនមានចំណេះដឹងអំពីបច្ចេកវិទ្យាគ្រប់គ្រាន់ ដើម្បីប្រើប្រាស់ប្រព័ន្ធអនឡាញបានដោយមានប្រសិទ្ធភាព។

៣. ទោះបើជាអ្នកជាប់ពន្ធបង់ប្រាក់សងពន្ធ ពន្ធបន្ថែម និងការប្រាក់ដែលនាំឱ្យឈានដល់ការរំលត់បណ្តឹងក៏ដោយ ការធ្វើបែបនេះនាំឱ្យខ្វះភាពច្បាស់លាស់អំពីស្ថានភាពរបស់អ្នកជាប់ពន្ធដែលអាចធ្វើឱ្យអ្នកជាប់ពន្ធនៅតែអាចប្រព្រឹត្តបទល្មើសពន្ធដារនៅពេលក្រោយបាន។

៤. បែបបទ និងនីតិវិធីនៃការអនុវត្តការស៊ើបអង្កេតគ្មានពេលវេលាកំណត់ច្បាស់លាស់ក្នុងជំហាននីមួយៗអាចបណ្តាលឱ្យមានភាពយឺតយ៉ាវក្នុងការអនុវត្តច្បាប់ស្តីពីសារពើពន្ធឱ្យមានប្រសិទ្ធិភាព។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

តាមការសិក្សាស្រាវជ្រាវទៅលើប្រធានបទ **នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ** រួចមក ធ្វើឱ្យយើងអាចសន្និដ្ឋាន រួមបានថា នីតិវិធីក្នុងការទប់ស្កាត់បទល្មើសរបស់អ្នកជាប់ពន្ធជាសំណុំនៃការរៀបចំវិធានការផ្លូវច្បាប់ដែលអាជ្ញាធរពាក់ព័ន្ធប្រើប្រាស់ដើម្បីស្រាវជ្រាវ ត្រួតពិនិត្យ និងទប់ស្កាត់ការបំពានច្បាប់ពន្ធ ដូចជាការបន្លំពន្ធ ការគេចវេះបង់ពន្ធ ឬបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ផ្សេងៗ។ នីតិវិធីនេះជាផ្នែកមួយនៃការអនុវត្តច្បាប់ពន្ធដើម្បីធានាបាននូវការយកពន្ធត្រឹមត្រូវ និងការពារសិទ្ធិនិងផលប្រយោជន៍របស់រដ្ឋ។ ទោះជាយ៉ាងណាក៏ដោយច្បាប់សារពើពន្ធ និងបទប្បញ្ញត្តិពាក់ព័ន្ធគឺបានចែងមិនទាន់គ្រប់ជ្រុងជ្រោយនៅឡើយនោះទេ ពោលគឺនៅមានភាពខ្វះចន្លោះមួយចំនួនទៀត ដែលត្រូវបំពេញបន្ថែម។ អ្នកជាប់ពន្ធនៅមានការយល់ដឹងតិចតួចនៅឡើយពីកាតព្វកិច្ចសារពើពន្ធ។ ទោះជាយ៉ាងណាក្តីបច្ចុប្បន្ននេះ ការបំពេញកាតព្វកិច្ចពន្ធពីសំណាក់អ្នកជាប់ពន្ធកាន់តែប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំតាមរយៈការកែទម្រង់របស់អគ្គនាយកដ្ឋានពន្ធដារដោយបានបញ្ជ្រាបវប្បធម៌បង់ពន្ធឱ្យបានកាន់តែទូលំទូលាយ។

## ៥.២ ការផ្តល់អនុសាសន៍

បន្ទាប់ពីការពិភាក្សាលើលទ្ធផលនៃការសិក្សាស្រាវជ្រាវរួចមក ក្រុមនាងខ្ញុំបានរកឃើញនូវចំណុចខ្លាំង និង ចំណុចខ្សោយមួយចំនួន ដើម្បីធ្វើការកែលម្អនូវចំណុចខ្សោយឱ្យមានភាពល្អប្រសើរ យើងខ្ញុំសូមផ្តល់នូវអនុសាសន៍ មួយចំនួនដូចតទៅ៖

❈ រដ្ឋបាលសារពើពន្ធគួរតែកំណត់យុទ្ធសាស្រ្តត្រួតពិនិត្យ និងស្វែងរកអាជីវកម្មដែលមិនបានចុះបញ្ជីដោយដាក់ពិន័យតឹងរឹង និងដាក់ចេញគោលនយោបាយលើកទឹកចិត្តឱ្យអ្នកជាប់ពន្ធមកចុះបញ្ជីដោយស្ម័គ្រចិត្ត។

❈ រដ្ឋបាលសារពើពន្ធគួរតែផ្តល់ការបណ្តុះបណ្តាល និងសិក្ខាសាលាចល័តទៅតាមសហគមន៍នានា និងបង្កើតបណ្តាញជំនួយបច្ចេកទេសតាមទូរស័ព្ទ ឬតាមវេបសាយដើម្បីឱ្យអ្នកជាប់ពន្ធយល់ដឹងកាន់តែច្បាស់អំពីការបង់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិក។

❈ រដ្ឋបាលសារពើពន្ធគួរតែដាក់ចេញនូវវិធានការតឹងរឹងចំពោះអ្នកជាប់ពន្ធដែលធ្លាប់ប្រព្រឹត្តបទល្មើសពន្ធដារ ដើម្បីឱ្យអ្នកជាប់ពន្ធដឹងពីផលវិបាកនៃការប្រព្រឹត្តបទល្មើសពន្ធដារ និងបង់ពន្ធឱ្យបានត្រឹមត្រូវ។

❈ រដ្ឋបាលសារពើពន្ធគួរតែកំណត់រយៈពេលច្បាស់លាស់សម្រាប់ដំណាក់កាលនីមួយៗក្នុងដំណើរការស៊ើបអង្កេត ដើម្បីបង្កើនទំនុកចិត្តចំពោះប្រព័ន្ធពន្ធដារ ក្នុងការអនុវត្តច្បាប់ស្តីពីសារពើពន្ធ។

# ឯកសារយោង


1. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ. (១៩៩៩). *ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង* លេខលិខិតៈ នស/រកម/០១.៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ២៧ទំព័រ។
2. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ. (១៩៩៥). *ច្បាប់ស្តីពីហិរញ្ញវត្ថុ* ព្រះរាជក្រមលេខ ១១ ន.ស ៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ។
3. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ. (២០១៨). *ប្រកាសស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃអគ្គនាយកដ្ឋានពន្ធដារ* លេខ១២៣២ សហវ .ប្រក ៦១ទំព័រ
4. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ. (២០២៤). *សៀវភៅណែនាំ ស្តីពីការសើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ* ៣២ទំព័រ
5. វិទ្យាស្ថាន វ៉ាន់ដា. (២០២២). *សៀវភៅគណនេយ្យអនុវត្តន៍ និងពន្ធ ភាគ១.* បោះពុម្ពលើកទី៣ ១៩០ ទំព័រ. ភ្នំពេញ។
6. Gov.Kh. (២០.០៩.២០២២). *ការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន.* Retrieved from https://share.google/mNvzSBW0kFTm0IP0g. (Accessed 16.03.2025)
7. CCC. (២០២០). *ការប្រកាសពន្ធតាមប្រព័ន្ធអនឡាញ.* Retrieved from www.ccc-cambodia.org (Accessed 16.03.2025)
8. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ. *ប្រកាសស្តីពីការចុះបញ្ជីពន្ធដារ* បោះពុម្ពផ្សាយ ថ្ងៃទី៦ ខែមេសា ឆ្នាំ ២០១៦ ៩ទំព័រ។
9. Kleng chomnes. (2021, November 09). *បទល្មើសពន្ធដារ.* Retrieved from https://g.co/kgs/hCaHKRR. (Accessed 16.03.2025)
10. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ. (១៩៩៧). *ច្បាប់ស្តីពីសារពើពន្ធ.* ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ៨៤ទំព័រ។

# ឧបសម្ព័ន្ធ


អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION
សៀវភៅណែនាំ ស្តីពី
ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ
លើបទប្បញ្ញត្តិស្តីពីពន្ធដារ
សម្រាប់មន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ០៦៦២១៤ អពដ

L20190607002 | TD1908

ថ្ងៃអង្គារ ៧រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ កក្កដា ឆ្នាំ២០១៩

# សេចក្ដីជូនដំណឹង
# ស្ដីពី
# វិធានការទប់ស្កាត់ការគេចវេះពន្ធ
# និងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជន លោក -លោកស្រីជាប្រធានក្រុមប្រឹក្សាភិបាល អភិបាល បណ្ណាធិការ ឬជាកម្មសិទ្ធិករនៃសហគ្រាសទាំងអស់ឱ្យបានជ្រាបថា កន្លងមកអគ្គនាយកដ្ឋានពន្ធដារបានកត់សម្គាល់ឃើញថា មានបុគ្គលទុច្ចរិតមួយចំនួនបានអួសអាញ បោកបញ្ឆោតបុគ្គលផ្សេងទៀតដែលមានការយល់ដឹងទាប ឱ្យឈរឈ្មោះជាម្ចាស់ភាគហ៊ុន និងជាអភិបាលបង្កើតក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម និងចុះបញ្ជីពន្ធដារនៅអគ្គនាយកដ្ឋានពន្ធដារដើម្បីទទួលបានវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ដើម្បីយកទៅប្រើប្រាស់ចេញវិក្កយបត្រក្លែងក្លាយទៅឱ្យក្រុមហ៊ុនមួយផ្សេងទៀតក្នុងគោលបំណងក្លែងបន្លំដាក់បញ្ចូលជាឥណទានអាករលើធាតុចូលសម្រាប់កាត់កងអាករលើធាតុចេញ និងបញ្ចូលជាបន្ទុកចំណាយដើម្បីកាត់បន្ថយពន្ធលើប្រាក់ចំណូល។

អំពើទាំងអស់ខាងលើនេះ ជាសកម្មភាពប្រព្រឹត្តបទល្មើសគេចវេះពន្ធ ដូចមានចែងក្នុងមាត្រា ១២៧ នៃច្បាប់ស្ដីពីសារពើពន្ធ ដែលត្រូវរងការផ្ដន្ទាទោសតាមមាត្រា ១៣៥ នៃច្បាប់ស្ដីពីសារពើពន្ធដែលបានចែងថា÷

*"ដោយមិនគិតដល់ទោសទណ្ឌផ្សេងទៀត អភិបាល បណ្ណាធិការ កម្មសិទ្ធិកររបស់សហគ្រាសណាមួយ ឬបុគ្គលទទួលខុសត្រូវឱ្យសហគ្រាសណាមួយដែលបានប្រព្រឹត្តអំពើគេចវេះពន្ធដូចមានចែងក្នុងមាត្រា ១២៧ នៃច្បាប់នេះ ត្រូវរងនូវការផ្ដន្ទាទោសពិន័យជាប្រាក់ពី ១០ ០០០ ០០០ រៀល(ដប់លានរៀល) ដល់ ២០ ០០០ ០០០ រៀល(ម្ភៃលានរៀល) ឬជាប់ពន្ធនាគារពី ១ ឆ្នាំ ដល់ ៥ ឆ្នាំ ឬទោសទាំងពីរនេះ"។*

និងជាបទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារដូចមានចែងក្នុងមាត្រា ១២៨ និង ១២៩ នៃច្បាប់ស្ដីពីសារពើពន្ធ ដែលត្រូវរងការផ្ដន្ទាទោសតាមមាត្រា ១៣៦ នៃច្បាប់ស្ដីពីសារពើពន្ធដែលបានចែងថា÷

*"ដោយមិនគិតដល់ទោសទណ្ឌផ្សេងទៀត បុគ្គលណាមួយដែលបានប្រព្រឹត្តអំពើរាំងស្ទះ ដល់ការអនុវត្តបទប្បញ្ញត្តិស្ដីពីពន្ធដារ ដូចមានចែងក្នុងមាត្រា ១២៨ នៃច្បាប់នេះ ត្រូវរងការផ្ដន្ទាទោសពិន័យជាប្រាក់ពី ៥ ០០០ ០០០ រៀល(ប្រាំលានរៀល) ដល់ ១០ ០០០ ០០០ រៀល(ដប់លានរៀល) ឬជាប់ពន្ធនាគារពី ១ ខែ ដល់ ១ ឆ្នាំ ឬទោសទាំងពីរនេះ។"*



អគារលេខមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និង ផ្លូវលេខ (២៨៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ( +855 ) 23 886 708 ទូរសារ: ( +855 )23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

L20190607002 | TD1908

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងចាត់វិធានការចាំបាច់នានាតាមច្បាប់ជាធរមាន ដើម្បីស្វែងរកបុគ្គលដែលបានប្រព្រឹត្តបទល្មើសមកផ្តន្ទាទោសតាមច្បាប់។

ដើម្បីពង្រឹងនូវការអនុវត្តច្បាប់ និងធានានូវតម្លាភាពនៃការប្រកួតប្រជែងក្នុងកិច្ចការធុរកិច្ច អគ្គនាយកដ្ឋានពន្ធដារ សូមស្នើសាធារណជន និងធុរជនទាំងអស់ រួមទាំងបុគ្គលដែលត្រូវបានគេជួលឱ្យឈរឈ្មោះជំនួស សហការផ្តល់ព័ត៌មានអំពីសកម្មភាពប្រព្រឹត្តបទល្មើសគេចវេះពន្ធ និងបទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារមកនាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារនៃអគ្គនាយកដ្ឋានពន្ធដារ តាមរយៈលេខទូរស័ព្ទ៖ ០២៣ ៨៨៤ ៧១៤ អ៊ីម៉ែល៖ dtci@tax.gov.kh ដើម្បីអគ្គនាយកដ្ឋានពន្ធដារចាត់វិធានការពង្រឹងការអនុវត្តច្បាប់ កាត់បន្ថយនូវការគេចវេះពន្ធឱ្យបានជាអតិបរមា។

ដូច្នេះដើម្បីជៀសវាងនូវទោសទណ្ឌដែលអាចកើតមានឡើងពីការប្រព្រឹត្តបទល្មើសទាំងនេះ អគ្គនាយកដ្ឋានពន្ធដារ សូមស្នើសាធារណជន និងធុរជនទាំងអស់ជៀសវាងនូវការប្រព្រឹត្តបទល្មើសខាងលើ និងអនុវត្តច្បាប់ស្តីពីសារពើពន្ធឱ្យបានត្រឹមត្រូវ។

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមយ៉ាងមុតមាំថា សាធារណជន លោក-លោកស្រីជាប្រធានក្រុមប្រឹក្សាភិបាល អភិបាល បណ្ណាធិការ ឬជាកម្មសិទ្ធិករនៃសហគ្រាសទាំងអស់ ពិតជាយកចិត្តទុកដាក់ និងសហការអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ.............................អពដ

AU2023 **ឧបសម្ព័ន្ធទី១**

ថ្ងៃ ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៣

**សេចក្តីជូនដំណឹង**
**ស្តីពី**
**ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ**

**ជម្រាបជូនលោក លោកស្រីនាយកក្រុមហ៊ុន**

ឈ្មោះក្រុមហ៊ុន :
ជាអក្សរឡាតាំង :
លេខអត្តសញ្ញាណកម្ម : ចុះបញ្ជីនៅ៖
សកម្មភាពអាជីវកម្ម :
អាសយដ្ឋាន :

អនុលោមតាមបទប្បញ្ញត្តិស្តីពីពន្ធដារ អគ្គនាយកដ្ឋានពន្ធដារសូមចាត់បញ្ជូនមន្ត្រីស៊ើបអង្កេតនៃនាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ ធ្វើការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារលើក្រុមហ៊ុនរបស់លោក លោកស្រី ចំពោះការបំពេញកាតព្វកិច្ចសារពើពន្ធក្នុងឆ្នាំជាប់ពន្ធ ០១-០១-២០១៨ ដល់៣១-១២-២០២០។

អាស្រ័យហេតុនេះ សូមលោក លោកស្រីមេត្តារៀបចំបញ្ជីកាតគណនេយ្យ កំណត់ត្រា លិខិតគតិយុត្ត វិក្កយបត្រ សក្ខីបត្រ ឯកសារផ្សេងៗ ឱ្យបានត្រឹមត្រូវ និងពេញលេញសម្រាប់បង្ហាញនិងផ្តល់ជូនមន្ត្រីស៊ើបអង្កេត។

លោក លោកស្រីអាចជ្រើសរើសទីប្រឹក្សា ដើម្បីជួយបញ្ជាក់បំភ្លឺអំពីបញ្ហាទាំងឡាយទាក់ទិននឹងការស៊ើបអង្កេតនេះ។

កាតព្វកិច្ចរបស់អ្នកជាប់ពន្ធ និងអំណាចរបស់រដ្ឋបាលសារពើពន្ធមាននៅក្នុងឧបសម្ព័ន្ធជូនភ្ជាប់មកជាមួយ។

សូមលោក លោកស្រីនាយកក្រុមហ៊ុន ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ

**អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

P712

**មន្ត្រីស៊ើបអង្កេត៖**
១. ២. ៣......

**ហត្ថលេខា និងត្រា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ........................អពដ

AU2023

**ឧបសម្ព័ន្ធទី២**

ថ្ងៃ          ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី    ខែ        ឆ្នាំ២០២៣

## លិខិតបញ្ជាបេសកកម្ម

**យោង ៖** - មាត្រា ១៩៤ និងមាត្រា ២៣០ នៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣និងបទប្បញ្ញត្តិស្តីពីពន្ធដារពាក់ព័ន្ធ
- លិខិតប្រគល់សិទ្ធិលេខ០៥៣ សហវ ចុះថ្ងៃទី០៤ ខែធ្នូឆ្នាំ២០១៣ របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

### រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
### ប្រតិភូរាជរដ្ឋាភិបាល
### ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ

សូមឧទ្ទេសនាមមន្ត្រីស៊ើបអង្កេតនៃនាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ ដូចមានរាយនាមខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១. | លោក | អគ្គលេខពន្ធដារ | អនុប្រធាននាយកដ្ឋាន | ប្រធានប្រតិភូ |
| ២. | លោក | អគ្គលេខពន្ធដារ | អនុប្រធាននាយកដ្ឋាន | អនុប្រធានប្រតិភូ |
| ៣. | លោក | អគ្គលេខពន្ធដារ | ប្រធានការិយាល័យ | អនុប្រធានប្រតិភូ |
| ៤. | លោក | អគ្គលេខពន្ធដារ | អនុប្រធានការិយាល័យ | សមាជិក |
| ៥. | លោក | អគ្គលេខពន្ធដារ | មន្ត្រី | សមាជិក |
| ៦. | លោក | អគ្គលេខពន្ធដារ | មន្ត្រី | សមាជិក |

ធ្វើដំណើរទៅកាន់ ៖ ក្រុមហ៊ុន
ជាឡាតាំង៖
លេខអ.ត.ប៖
អាសយដ្ឋាន៖
មានភារកិច្ច ៖ ស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ
ឆ្នាំជាប់ពន្ធ ៖ ០១-០១-២០១៨ ដល់ ៣១-១២-២០២០
កាលបរិច្ឆេទចេញដំណើរ ៖ ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៣
កាលបរិច្ឆេទត្រឡប់ ៖ រហូតដល់ថ្ងៃបញ្ចប់បេសកកម្ម
មធ្យោបាយធ្វើដំណើរ ៖ រថយន្ត

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលមានសមត្ថកិច្ចពាក់ព័ន្ធ មេត្តាជួយសម្រួលដល់បេសកកម្មនេះឱ្យសម្រេចដោយជោគជ័យ។

**អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**ហត្ថលេខា និងត្រា**

P71

**ចម្លងជូន ៖**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី កសហវ
- នាយកដ្ឋានបុគ្គលិក នៃអគ្គលេខាធិការដ្ឋាន កសហវ
*"ដើម្បីជូនជ្រាប"*
- រដ្ឋបាលរាជធានីខេត្ត
- សាខាពន្ធដាររាជធានី-ខេត្ត
*"ដើម្បីជូនជ្រាប និងសហការអនុវត្ត"*
- សាមីខ្លួន
*"ដើម្បីអនុវត្ត"*
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
*លេខ..........................អពដ*

**ឧបសម្ព័ន្ធទី៣**

L2023010: 96TD2869

*លេខសំណុំរឿង*
*ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២*

ថ្ងៃព្រហ ១៣កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០២៣

# លិខិតកោះហៅ (ដើមលិខិត)

**យើងជាមន្ត្រីនគរបាលយុត្តិធម៌**

យោង៖
- មាត្រា៨៤ មាត្រា១១១ មាត្រា១១២ និងមាត្រា១១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
- ការអនុញ្ញាតឱ្យបើកការស៊ើបអង្កេតបឋមរបស់ព្រះរាជអាជ្ញា ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០២៣ លើសំណុំរឿង៖ បទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដាររបស់សហគ្រាស

**កោះហៅ**

- ឈ្មោះ :
- លិខិតឆ្លងដែន :
- ជនជាតិ :
- ថ្ងៃ ខែ ឆ្នាំកំណើត :
- ទីកន្លែងកំណើត :
- ទីលំនៅបច្ចុប្បន្ន :
- មុខរបរ :
- លេខទូរស័ព្ទ :

**ឱ្យចូលមកកាន់** ៖ នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ បន្ទប់លេខ ..... អគារលេខ 92R ផ្លូវសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

**កាលបរិច្ឆេទ** ៖ នៅថ្ងៃទី ........ ខែ ............ ឆ្នាំ ......... វេលាម៉ោង .................... ព្រឹក/រសៀល

**ដើម្បី** ៖ ផ្តល់ចម្លើយពាក់ព័ន្ធនឹងប្រតិបត្តិការអាជីវកម្ម និងប្រតិបត្តិការធនាគាររបស់ សហគ្រាស

**មន្ត្រីទំនាក់ទំនង** ៖ ទូរស័ព្ទលេខ :

សាមីខ្លួនត្រូវអញ្ជើញមកតាមលិខិតកោះហៅនេះឲ្យទាន់ពេលវេលា និងយកមកជាមួយនូវ**ឯកសារពាក់ព័ន្ធនឹងករណីខាងលើ** ប្រសិនបើមាន។

បានប្រគល់លិខិតកោះហៅនេះឱ្យឈ្មោះ: ..............................................
នៅ.......................................ឃុំ/សង្កាត់...................................
ស្រុក/ខណ្ឌ .......................... ខេត្ត/រាជធានី ..................................
ម៉ោង.............នៅថ្ងៃទី...........ខែ.............ឆ្នាំ.................ផ្តល់រួចហើយ

លិខិតកោះហៅនេះ ធ្វើជាពីរច្បាប់ ដោយបានទុកមួយច្បាប់ឱ្យសាមីខ្លួន។

**អ្នកប្រគល់** **អ្នកទទួល**
**ហត្ថលេខា ឬស្នាមមេដៃ**

**មន្ត្រីនគរបាលយុត្តិធម៌**
**ជ. អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**ហត្ថលេខា និងត្រា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

លេខ.......................អពដ

AU2023

**ឧបសម្ព័ន្ធទី៤**

ថ្ងៃ ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៣

## លិខិតជូនដំណឹង
## ស្តីពីលទ្ធផលនៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ

**ជម្រាបជូនលោក លោកស្រីនាយកក្រុមហ៊ុន**

ឈ្មោះក្រុមហ៊ុន :
ជាអក្សរឡាតាំង :
លេខអត្តសញ្ញាណកម្ម : ចុះបញ្ជីនៅ៖
សកម្មភាពអាជីវកម្ម :
អាសយដ្ឋាន :

ខ្ញុំសូមជម្រាបជូន លោក លោកស្រីថាក្រុមហ៊ុនរបស់លោក លោកស្រីត្រូវបាន**ស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ**ចំពោះការបំពេញកាតព្វកិច្ចសារពើពន្ធ ក្នុងការិយបរិច្ឆេទ ថ្ងៃទី១ ខែមករា ឆ្នាំ២០២០ ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។

ដោយអនុលោមតាមមាត្រា២០៩ មាត្រា២១០ និងមាត្រា២១២ នៃច្បាប់ស្តីពីសារពើពន្ធ នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ សូមធ្វើការកែប្រែទិន្នន័យដែលជាមូលដ្ឋានសម្រាប់គណនាប្រាក់ពន្ធ-អាករនិងតម្រូវឱ្យលោក លោកស្រីបង់បន្ថែមនូវប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់ដូចខាងក្រោម៖

| ការិយបរិច្ឆេទ | ប្រាក់ពន្ធ | ពន្ធបន្ថែម | ការប្រាក់ | សរុប |
|---|---|---|---|---|
| 2020 | | | | |

**ព័ត៌មានលម្អិតស្តីពីប្រភេទពន្ធនិងទឹកប្រាក់ពន្ធ/INFORMATION OF TAX TYPES AND AMOUNT DETAIL**

| ល.រ | ខែឆ្នាំ | ប្រភេទពន្ធ | ទឹកប្រាក់ពន្ធ | ពន្ធបន្ថែម | ការប្រាក់ | សរុប |
|---|---|---|---|---|---|---|
| ១. | | | | | | |
| ២. | | | | | | |

លោក លោកស្រីមានរយៈពេល **៣០ថ្ងៃ** ក្រោយកាលបរិច្ឆេទនៃការប្រគល់លិខិតជូនដំណឹងនេះ សម្រាប់ឆ្លើយតបមកអគ្គនាយកដ្ឋានពន្ធដារវិញ នូវយោបល់ដែលអាចជាការយល់ព្រមឬជាការបដិសេធចំណែកណាមួយ ឬទាំងស្រុងចំពោះការកំណត់ពន្ធឡើងវិញនេះ ដោយត្រូវ មានភ្ជាប់ជាមួយឯកសារបញ្ជាក់ជាកស្តុតាងផង។ ការមិនបានឆ្លើយតបក្នុងរយៈពេលនេះ ចាត់ទុកថាលោក លោកស្រីបានយល់ព្រមតាមរដ្ឋបាលសារពើពន្ធ។

ក្នុងករណីលោក លោកស្រីមិនបានបង់ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់ដែលបានកំណត់ខាងលើនេះ លោក លោកស្រីអាចនឹងត្រូវ ទទួលរងនូវទោសទណ្ឌដទៃទៀត តាមច្បាប់ជាធរមាន។

សូមលោក លោកស្រីនាយកក្រុមហ៊ុន ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ

**អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

P712

**ហត្ថលេខា និងត្រា**

មន្ត្រីស៊ើបអង្កេត៖
១. ២. ៣......

ក្រុមប្រឹក្សាអ្នកច្បាប់
អគ្គលេខាធិការដ្ឋាន
ចូល លេខ: ១៦៦
ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០២៣
ម៉ោង: ១៥:០០

# ព្រះរាជក្រម

នស/រកម/០៥២៣/០០៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីសារពើពន្ធ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភា លើកទី៩ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៣ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅៈ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ [illegible] សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅ នៃអគ្គនាយកដ្ឋានពន្ធដារ

### ឧបនាយករដ្ឋមន្ត្រី

### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការដំឡើងវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការតម្លើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ តម្លើងនាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល ទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល និងបង្កើតនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មានស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១ ..**

ប្រកាសនេះ មានគោលបំណងកំណត់នូវការរៀបចំនិងការប្រព្រឹត្តទៅ នៃអគ្គនាយកដ្ឋានពន្ធដារ។

**ប្រការ២ ..**

ប្រកាសនេះ មានគោលដៅ ដូចខាងក្រោម÷

- រៀបចំទស្សនវិស័យ បេសកកម្ម ភារកិច្ច និងរចនាសម្ព័ន្ធរបស់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានពន្ធដារ
- រៀបចំមុខងារនិងភារកិច្ចរបស់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានពន្ធដារ ដើម្បីធានាគុណភាពនិងប្រសិទ្ធភាពនៃការបំពេញការងារពាក់ព័ន្ធនឹងពន្ធដារ។

**ប្រការ៣ ..**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។